# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម
នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម

# ការគ្រប់គ្រងសហគមន៍កសិកម្ម

សៀវភៅសម្រាប់បណ្តុះបណ្តាលសមាជិក ក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ
ដែលផ្តោតសំខាន់លើការបង្កើនសមាជិកភាពនិងប្រាក់ភាគហ៊ុន
នៅក្នុងព្រះរាជាណាចក្រកម្ពុជា

រៀបចំដោយៈ គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

ខែសីហា ឆ្នាំ២០១៦

**ការគ្រប់គ្រងសហគមន៍កសិកម្ម**

បោះពុម្ពផ្សាយ៖ ខែសីហា ឆ្នាំ២០១៦

បោះពុម្ពដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម (MAFF)

គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

អាសយដ្ឋាន៖ # ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ទូរស័ព្ទ៖ (០២៣) ៨៨៣ ៤២៧ ទូរសារ៖ (០២៣) ៨៨៣ ៤២៧

© គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

# ការគ្រប់គ្រងសហគមន៍កសិកម្ម

ផ្ដោតសំខាន់លើការបង្កើនសមាជិកភាពនិងប្រាក់ភាគហ៊ុន
នៅក្នុងព្រះរាជាណាចក្រកម្ពុជា

---

## មាតិកា

---


អារម្ភកថា ... ... ... ... ... ... ... ... ... 01

កំណត់ចំណាំសម្រាប់អ្នកប្រើប្រាស់សៀវភៅនេះ... ... ... ... ... ... 05

១ និយមន័យសហគមន៍កសិកម្ម ... ... ... ... ... ... ... 06

២ រចនាសម្ព័ន្ធនិងការគ្រប់គ្រងរបស់សហគមន៍កសិកម្ម... ... ... ... ... 11

៣ លក្ខន្តិកៈសហគមន៍កសិកម្ម ... ... ... ... ... ... ... ... 12

៤ កិច្ចប្រជុំនៅក្នុងសហគមន៍កសិកម្ម ... ... ... ... ... ... 14

៥ ប្រភពធនធាននិងសាច់ប្រាក់ចេញរបស់សហគមន៍កសិកម្ម ... ... ... ... 15

៦ មុខរបររបស់សហគមន៍កសិកម្ម ... ... ... ... ... ... ... 17

    ផ្នែកទី១ មុខរបរឥណទានរបស់សហគមន៍កសិកម្ម ... ... ... ... 18

    ផ្នែកទី២ មុខរបរទីផ្សាររបស់សហគមន៍កសិកម្ម... ... ... ... ... 21

    ផ្នែកទី៣ មុខរបរផ្គត់ផ្គង់របស់សហគមន៍កសិកម្ម ... ... ... ... 22

    ផ្នែកទី៤ សេវាកម្មផ្ដល់ដំបូន្មានកសិកម្មរបស់សហគមន៍កសិកម្ម... ... ... 23

៧ ការចូលរួមរបស់សមាជិកនៅក្នុងសហគមន៍កសិកម្ម ... ... ... ... ... 24

៨ តម្លាភាពនិងគណនេយ្យភាពនៅក្នុងសហគមន៍កសិកម្ម ... ... ... ... 26

៩ ការបង្កើនសមាជិកភាព ប្រាក់ភាគហ៊ុន និងអភិបាលកិច្ច ... ... ... ... 28

អំពីអ្នកនិពន្ធ ... ... ... ... ... ... ... ... ... ... 37


---

# អារម្ភកថា

សហគមន៍កសិកម្មនៅទូទាំងពិភពលោក បាននិងកំពុងចូលរួមចំណែកយ៉ាងសំខាន់ នៅក្នុងការផ្គត់ផ្គង់ស្បៀង។ សហគមន៍ បានផ្តល់ជាការងារនិងប្រភពប្រាក់ចំណូលដល់កសិករនិងជនដទៃផ្សេងទៀតដែលពឹងផ្អែកលើកសិកម្ម។ សហគមន៍កសិកម្មប្រព្រឹត្តទៅយ៉ាងមានប្រសិទ្ធភាពលើគោលជំហរពីរគឺភាពសកម្ម និងភាពចេះដឹងរបស់សមាជិក និងដើមទុនគ្រប់គ្រាន់។ សមាជិកនិងដើមទុនច្រើន ជាកត្តាធ្វើឱ្យសហគមន៍កសិកម្មទទួលបានភាពជោគជ័យ។ សហគមន៍គ្រប់ប្រភេទទាំងអស់នៅទូទាំងពិភពលោកបានទទួលនូវភាពជោគជ័យក៏ព្រោះតែមានការចូលរួមប្រើប្រាស់ពីសមាជិក។ កំរិតខ្ពស់នៃការប្រើប្រាស់ អាចជាការចូលរួមយ៉ាងសកម្មរបស់សមាជិក ការបង្កើនទុននិងទុនដែលមានស្រាប់នៅក្នុងសហគមន៍កសិកម្ម។

តាមការកត់សម្គាល់បានបង្ហាញថាសមាជិកសហគមន៍កសិកម្មភាគច្រើនជាកសិករក្រីក្រដែលពុំមានថវិកា និងឧបករណ៍គ្រប់គ្រាន់ ក្នុងការប្រកបការងារកសិកម្មដោយខ្លួនឯងផ្ទាល់ និងដោយធនធានរបស់ខ្លួនផ្ទាល់។ កសិករជាអ្នកមាន អាចគ្រប់គ្រងការប្រកបរបរកសិកម្មបាន ដោយពួកគេអាចទិញម៉ាស៊ីនកសិកម្ម បង្កើតហេដ្ឋារចនាសម្ព័ន្ធ និងជួលមនុស្សដើម្បីគាំទ្រដល់ការធ្វើកសិកម្មបាន។ កសិករជាអ្នកមាន អាចរៀបចំបរិក្ខារជារាសាស្ត្រក៏ដូចជាការកែលម្អដីដោយខ្លួនឯងបានប៉ុន្តែកសិករប្រភេទនេះ គឺមានតិចតួច ហើយក៏មិនមាននៅក្នុងគ្រប់ប្រទេសដែរ ។

កសិករនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប និងកសិករដែលមិនមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ជាទូទៅចូលរួមក្នុងសហគមន៍កសិកម្មដើម្បីទទួលបានការគាំទ្រ ដោយពួកគេអាចទទួលបានប្រាក់កម្ចីសម្រាប់ការកែលម្អដី ការទិញជាតុចូល ការច្រូតកាត់ ឃ្លាំង និងការដឹកជញ្ជូន។ ពួកគេអាចគ្រប់គ្រងកំលាំងពលកម្មសម្រាប់ការប្រកបរបរកសិកម្ម។ ហេតុដូច្នេះសហគមន៍កសិកម្ម បានឈរនៅក្បែរសមាជិក និងផ្តល់នូវការគាំទ្រគ្រប់គ្រាន់និងទាន់ពេលវេលាដល់ពួកគាត់ដោយផ្តល់ឱ្យពួកគាត់នូវប្រាក់កម្ចីទាន់ពេលវេលា និងបង្កើតជាហេដ្ឋារចនាសម្ព័ន្ធកសិកម្មសម្រាប់ពួកគាត់។ ហេតុដូច្នេះសហគមន៍កសិកម្ម គួរតែមានសក្តានុពលដើម្បីផ្គត់ផ្គង់តម្រូវការរបស់សមាជិករបស់ខ្លួន។ ចំណែកឯសមាជិកវិញត្រូវចូលរួមគ្រប់សកម្មភាពរបស់សហគមន៍កសិកម្ម ដើម្បីជានាសុវត្ថិភាពនៃសេវាកម្មរបស់សហគមន៍កសិកម្មរបស់ពួកគេ។

ការចូលរួមរបស់សមាជិក គឺជាកត្តាសំខាន់ចំពោះគ្រប់សហគមន៍កសិកម្មទាំងអស់។ ការចូលរួមនៅក្នុងទីនេះ គឺសំដៅទៅលើការចូលរួមនៅក្នុងផ្នែករចនាសម្ព័ន្ធ ការគ្រប់គ្រង និងហិរញ្ញវត្ថុ។ វាគឺជាការចាំបាច់ដែលសមាជិកត្រូវចូលរួមគ្រប់ការប្រជុំ។ សមាជិក ចូលរួមក្នុងសកម្មភាពប្រជាធិបតេយ្យ ដូចជាការបោះឆ្នោតជ្រើសរើសបុគ្គលត្រឹមត្រូវជាក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ។ សមាជិក គួរតែ

មានសេរីភាពក្នុងការសាកសួរនិងធ្វើការស្នើសុំក៏ដូចជាការអង្កេតពីការប្រជុំ។ សមាជិកគួរតែធ្វើការស្នើសុំដើម្បីផ្លាស់ប្តូរលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងនិងផ្នែកផ្សេងៗទៀតក្នុងការគ្រប់គ្រង។ ថ្នាក់ដឹកនាំសហគមន៍កសិកម្មមិនអាចប្រើអំណាចដើម្បីត្រួតត្រាសមាជិកនោះទេគឺថាសមាជិកមានសិទ្ធិសេរីភាពនិងឯករាជ្យ ។

សហគមន៍កសិកម្មនិងសមាជិកនៅក្នុងប្រទេសទាំងអស់ ត្រូវការឥណទានដើម្បីប្រកបរបរកសិកម្ម។ សហគមន៍កសិកម្ម ប្រើប្រាស់ដើមទុនរបស់សហគមន៍និងប្រាក់កម្ចីពីខាងក្រៅ ដើម្បីផ្តល់ឥណទានដល់សមាជិក ។ ហេតុដូច្នេះ សហគមន៍កសិកម្ម គួរតែបង្កើតនូវដើមទុននិងមូលនិធិដទៃទៀតក្នុងកំរិតខ្ពស់ ដើម្បីមានលទ្ធភាពផ្តល់ឥណទានដល់សមាជិក ដែលជាឥណទានរយៈពេលខ្លីឬមធ្យម ក្នុងអត្រាការប្រាក់មួយសមស្រប។ ការប្រាក់នៃឥណទានសហគមន៍នៅក្នុងប្រទេសមួយចំនួននៅក្នុងពិភពលោក គឺទាបជាងអត្រាការប្រាក់ទីផ្សារ។ ហេតុដូច្នេះ សហគមន៍កសិកម្ម គួរតែបង្កើតនូវដើមទុនក្នុងកំរិតសមរម្យដោយប្រើវិធីបង្កើនប្រាក់ភាគហ៊ុននិងមូលនិធិផ្សេងៗទៀត។ សហគមន៍កសិកម្មទាំងនេះ គឺមិនមែនជា សហគ្រាសដែលផ្តល់ប្រាក់កម្ចីតែមួយមុខនោះទេ។ សហគមន៍កសិកម្ម មិនអាចនិងមិនគួរប្រើប្រាស់ដើមទុនទាំងអស់សម្រាប់ឥណទានទេ។ ទាំងនេះគឺខុសគ្នាពីក្រុមអ្នកផ្តល់ប្រាក់កម្ចីឯកជន។ សហគមន៍កសិកម្ម មិនកេងចំណេញពីសមាជិកដូចអ្នកផ្តល់ប្រាក់កម្ចីមួយចំនួននោះទេ។ សហគមន៍កសិកម្ម ផ្តល់សេវាកម្មឥណទានដែលមានភាពត្រឹមត្រូវនិងសុវត្ថិភាពដល់កសិករជាសមាជិក។

ហេតុដូច្នេះ សហគមន៍កសិកម្មត្រូវតែបង្កើនប្រាក់ភាគហ៊ុននិងត្រូវរក្សាមូលនិធិពីប្រភពផ្សេងៗ ដូចជារដ្ឋាភិបាល ធនាគារសហគមន៍។ល។ ថវិកា អាចត្រូវបានប្រមូលពីការដាក់បញ្ញើសន្សំដោយស្ម័គ្រចិត្តនិងជាកាតព្វកិច្ចពីសមាជិក ជាមួយនឹងការសងត្រលប់វិញដោយក្តីទុកចិត្ត។ វាគួរតែចាំក្នុងចិត្តថាសហគមន៍កសិកម្ម មិនមែនជាសហគ្រាសផ្តល់ប្រាក់កម្ចីនោះទេ គឺថាសហគមន៍កសិកម្ម គឺជាស្ថាប័នស្របច្បាប់និងផ្តល់ប្រាក់កម្ចីក្នុងអត្រាការប្រាក់សមស្រប ដោយមិនត្រូវបានប៉ះពាល់ពីអត្រាការប្រាក់ទីផ្សារឡើយ។ ឥណទានដែលត្រូវបានពង្រីក ត្រូវតែសងត្រលប់មកវិញជាមួយនឹងការប្រាក់គ្រប់ចំនួននិងទាន់ពេលវេលាសម្រាប់បន្តឥណទានទៅមុខទៀត។

ហេតុដូច្នេះ សហគមន៍កសិកម្ម ត្រូវតែផ្តល់សេវាកម្មបន្ថែមដល់សមាជិករបស់ខ្លួនដូចជាទីផ្សារផលិតផលរបស់សមាជិក ផ្គត់ផ្គង់ធាតុចូលកសិកម្មនិងតម្រូវការប្រចាំថ្ងៃ និងដំបូន្មានបច្ចេកទេសកសិកម្ម ក្រៅពីសេវាកម្មឥណទាន។ ការផ្តល់ប្រាក់កម្ចីពីដើមទុនផ្ទាល់របស់សហគមន៍ គឺមិនមែនជាមុខងារតែមួយរបស់សហគមន៍កសិកម្មទេ។ សហគមន៍កសិកម្ម គឺមិនមែនជាអ្នកផ្តល់ប្រាក់កម្ចីនោះទេ។ ពួកគេ ផ្តល់ប្រាក់កម្ចីដល់សមាជិកដោយបង្កើនធនធានពីប្រភពផ្សេងៗហើយធនធានទាំងនេះ គឺត្រូវចំណាយថវិកា( ក្នុងទំរង់ជាការប្រាក់ )។

គោលបំណងសំខាន់របស់សៀវភៅនេះ គឺដើម្បីជួយដល់មន្ត្រីទទួលបន្ទុកក្នុងការអភិវឌ្ឍសហគមន៍កសិកម្ម និងមន្ត្រីរបស់សហគមន៍កសិកម្ម ឱ្យមានលទ្ធភាពពន្យល់ដល់សមាជិកសហគមន៍កសិកម្មនូវសារៈសំខាន់នៃការបង្កើនសមាជិកភាពនិងប្រាក់ភាគហ៊ុន។ សមាជិកភាពសហគមន៍កសិកម្មគឺបានមកពីសហគមន៍រស់នៅដែលសហគមន៍តាំងនៅ ។

វាគួរតែចងចាំដែរថា គ្រប់ៗគ្នារួមមានសមាជិកក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ ក្រុមអ្នកអភិវឌ្ឍន៍សហគមន៍ ថែមទាំងមន្ត្រីដែលទទួលបន្ទុកក្នុងការអភិវឌ្ឍន៍សហគមន៍កសិកម្ម គួរតែជំរុញលើកទឹកចិត្តដល់សហគមន៍កសិកម្មក្នុងការបង្កើនដើមទុន ។ ដើមទុន ប្រៀបបានជាទ្រព្យសម្បត្តិ ហើយវាមិនគួរត្រូវបានទុកដើម្បីផ្តល់ជូនក្នុងចំណោមសមាជិកដោយគ្មានការប្រុងប្រយ័ត្ននោះទេ ។ សេចក្តីសម្រេចក្នុងការប្រើប្រាស់ដើមទុនត្រូវតែធ្វើឡើងដោយសមហេតុផល។ ដើមទុនប្រមូលបានគឺមិនមែនសម្រាប់តែផ្តល់ប្រាក់កម្ចីនោះទេ ។

គោលការណ៍ទី៣ នៃគោលការណ៍គ្រឹះរបស់សម្ព័ន្ធសហករណ៍អន្តរជាតិ បានចែងថាសមាជិកជាទូទៅទទួលបានប្រាក់ភាគលាភមានកំណត់ បើសិនជាមាន ចំពោះដើមទុនដែលបានចូលរួមក្នុងលក្ខខណ្ឌជាសមាជិកភាព។ សមាជិក បែងចែកប្រាក់ចំណេញទៅតាមគោលបំណងដូចខាងក្រោម៖ ការអភិវឌ្ឍសហគមន៍ ដោយបង្កើតជាមូលនិធិបម្រុងដែលជាផ្នែកមិនអាចបែងចែក ការផ្តល់ប្រាក់លើកទឹកចិត្តសមាជិកដោយសមាមាត្រទៅនឹងការប្រតិបត្តិការជំនួញជាមួយសហគមន៍ និងការគាំទ្រសកម្មភាពផ្សេងៗទៀត ដែលបានសម្រេចដោយសមាជិក។ នៅក្នុងអត្ថន័យនៃគោលគំនិតនេះ សហគមន៍កសិកម្ម ត្រូវរក្សាទុកប្រាក់ចំណេញមួយចំនួនដែលទទួលបានពីការប្រកបមុខរបរក្នុងសហគមន៍ ដោយមិនត្រូវផ្តល់ប្រាក់ភាគលាភក្នុងអត្រាខ្ពស់ពេកដល់សមាជិកឡើយហើយត្រូវប្រើប្រាស់នៅក្នុងផ្លូវត្រូវជាមួយនឹងមូលនិធិផ្សេងៗទៀត (ប្រាក់ភាគហ៊ុន ប្រាក់បញ្ញើសន្សំ និងមូលនិធិផ្សេងៗទៀត) ដោយមិនត្រូវទុកសម្រាប់ជាប្រាក់កម្ចីទាំងស្រុងឡើយ និងមិនបានទុកអ្វីសោះជាទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្មនោះទេ។

ដោយមានប្រាក់លើកលើកទឹកចិត្ត សមាជិកជាច្រើននៅក្នុងសហគមន៍ជនបទ នឹងមានចំណាប់អារម្មណ៍ចង់ក្លាយជាសមាជិកសហគមន៍កសិកម្ម ហេតុដូច្នេះ សមាជិកគួរតែត្រូវបានណែនាំអំពីអត្ថប្រយោជន៍ដែលសហគមន៍កសិកម្មអាចផ្តល់ឱ្យបាន។ ដូចគ្នានេះដែរ សមាជិក នឹងត្រូវទិញភាគហ៊ុនដើម្បីទទួលបានផលប្រយោជន៍ពីសេវាកម្ម ហេតុដូច្នេះ មន្ត្រីដែលទទួលបន្ទុកក្នុងការអភិវឌ្ឍសហគមន៍កសិកម្ម គួរតែផ្តល់ការពន្យល់អោយបានច្បាស់លាស់ពីអត្ថប្រយោជន៍ក្នុងការចូលជាសមាជិករបស់សហគមន៍កសិកម្ម និងជំរុញប្រជាកសិករឱ្យចូលរួមនៅក្នុងសហគមន៍កសិកម្មរបស់ពួកគេ។

មន្ត្រីដែលទទួលបន្ទុកក្នុងការអភិវឌ្ឍន៍សហគមន៍កសិកម្ម និងមន្ត្រីរបស់សហគមន៍កសិកម្ម ត្រូវតែយល់អោយច្បាស់ពីរចនាសម្ព័ន្ធគ្រប់គ្រងរបស់សហគមន៍កសិកម្ម។ ពួកគេគួរតែយល់ដឹងអំពីគុណសម្បត្តិនៃមុខរបរឥណទាននិងមុខរបរដទៃផ្សេងទៀតរបស់សហគមន៍កសិកម្ម ដែលមានភាពខុសគ្នាពីសហគ្រាសឯកជន។

យើងសង្ឃឹមថាអ្វីដែលបង្ហាញនៅក្នុងសៀវភៅនេះ នឹងក្លាយជាធាតុចូលសម្រាប់មន្ត្រីដែលទទួលបន្ទុកក្នុងការអភិវឌ្ឍសហគមន៍កសិកម្ម ថ្នាក់ដឹកនាំ និងសមាជិករបស់សហគមន៍កសិកម្មសម្រាប់យកទៅប្រើប្រាស់។

Masahiro Matsuda
Daman Prakash

# កំណត់ចំណាំសម្រាប់អ្នកប្រើប្រាស់សៀវភៅនេះ

សៀវភៅនេះ មានបំណងបង្កើតការយល់ដឹងដល់សមាជិកនិងថ្នាក់ដឹកនាំសហគមន៍កសិកម្ម ជាមួយនឹងគំនិតក្នុងការបង្កើនចំណាប់អារម្មណ៍ និងការចូលរួមសេដ្ឋកិច្ចនៅក្នុងសហគមន៍កសិកម្ម។ ហេតុដូច្នេះ សៀវភៅមួយនេះ ត្រូវបានរៀបចំឡើងជាឯកសារសម្រាប់បង្រៀន ។

ខ្លឹមសារដែលមាននៅក្នុងសៀវភៅនេះ គឺជាមូលដ្ឋានគ្រឹះនិងផ្តោតសំខាន់លើកសិករដែលជាសមាជិកសហគមន៍កសិកម្ម។ កសិករដែលជាសមាជិក គួរតែដឹកនាំសហគមន៍កសិកម្មរបស់ពួកគេជាលក្ខណៈប្រជាធិបតេយ្យ។ សហគមន៍កសិកម្មទាំងនេះ គួរតែមានលទ្ធភាពផ្តល់ជូនសមាជិកនូវសេវាកម្មសំខាន់ៗសម្រាប់គាំទ្រដល់ការងារ។ ជាការពិតណាស់ សេវាកម្មឥណទាន គឺមានសារៈសំខាន់ ប៉ុន្តែមិនត្រូវប្រើប្រាស់ដើមទុនរបស់សហគមន៍កសិកម្មផ្ទាល់ទាំងអស់នោះទេ។ ដើមទុនរបស់សហគមន៍ គួរតែត្រូវបានប្រើប្រាស់សម្រាប់សេវាកម្មផ្សេងទៀតផងដែរ។ បញ្ហានេះ ត្រូវតែបញ្ជាក់នៅក្នុងអំឡុងពេលបណ្តុះបណ្តាល។

ហេតុដូច្នេះ អ្នកប្រើប្រាស់សៀវភៅនេះ គួរតែអានខ្លឹមសារដោយយកចិត្តទុកដាក់ ទើបពួកគេយល់ពីគំនិតនិងដំណើរការនៃសហគមន៍កសិកម្ម។ ពួកគេ គួរតែយល់ឱ្យបានច្បាស់ថា សហគមន៍កសិកម្ម មិនមែនជាភ្នាក់ងារផ្តល់ប្រាក់កម្ចីតែមួយនោះទេ វាមានមុខងារជាច្រើនផ្សេងទៀត។ ខ្លឹមសារសៀវភៅនេះ អាចត្រូវបានបែងចែកជា២ផ្នែកគឺ ទី(១) ការផ្តល់ព័ត៌មានដល់សមាជិក និងទី(២) ការជំរុញសមាជិកសហគមន៍កសិកម្មដើម្បីធ្វើការស្នើសុំអំពីសេវាកម្មនានារបស់សហគមន៍កសិកម្ម។

សេចក្តីសង្ខេប គួរតែត្រូវបានធ្វើឡើងសម្រាប់សិក្ខាកាមនៅចុងបញ្ចប់នៃកម្មវិធីបង្រៀន។ សិក្ខាកាម អាចជាសមាជិកសហគមន៍កសិកម្មរួមទាំងសមាជិកក្រុមប្រឹក្សាភិបាលផងដែរ។

មន្ត្រីដែលទទួលបន្ទុកក្នុងការងារអភិវឌ្ឍសហគមន៍កសិកម្មត្រូវតែពន្យល់កសិករ និង ការផ្តល់ប្រាក់កម្ចីគឺមិនមែនជាគោលបំណងរបស់សហគមន៍កសិកម្មតែមួយនោះទេ ហើយការផ្តល់ប្រាក់ភាគលាភជូនដល់សមាជិក ត្រូវតែមានកំណត់ ដើម្បីបង្កើនដើមទុនរបស់សហគមន៍កសិកម្ម ដើម្បីវិនិយោគនៅក្នុងមុខរបរថ្មី និង/ឬ មុខរបរមានស្រាប់ដែលអាចផ្តល់ផលប្រយោជន៍ដល់សមាជិក។ ការកំណត់ការប្រាក់ស្មើឬខ្ពស់ជាងអត្រាការប្រាក់ទីផ្សារ គឺមិនមែនជាគោលបំណងរបស់សហគមន៍កសិកម្មនោះទេ។

---

# ជំពូកទី១
# និយមន័យសហគមន៍កសិកម្ម

## និយមន័យ

ខាងក្រោមនេះគឺជានិយមន័យនៃសហគមន៍/សហករណ៍ដែលទទួលស្គាល់ទូទាំងពិភពលោក ។

"សហគមន៍/សហករណ៍គឺជាសមាគមស្វយ័តនៃមនុស្សមួយក្រុមដែលប្រមូលផ្តុំគ្នាដោយស្ម័គ្រចិត្តដើម្បីបំពេញតម្រូវការសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងសេចក្តីប៉ងប្រាថ្នា តាមរយៈការធ្វើជាម្ចាស់រួមគ្នា និងគ្រប់គ្រងសហគមន៍តាមលក្ខណៈប្រជាធិបតេយ្យ។"

ដូចគ្នានេះដែរ សហគមន៍កសិកម្ម ក៏អាចកំណត់និយមន័យបានដូចខាងក្រោម៖

"សហគមន៍ (កសិកម្ម) គឺជាសមាគមស្វយ័តនៃមនុស្សមួយក្រុម (កសិករ អ្នកជួលដី កសិករគ្មានដី កសិករផលិតទឹកដោះគោ អ្នកកែច្នៃផលិតផលកសិកម្ម ទាំងស្រីនិងប្រុស) ដែលប្រមូលផ្តុំគ្នាដោយស្ម័គ្រចិត្ត ដើម្បីបំពេញតម្រូវការសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ឥណទាន ជាតុចូលកសិកម្ម ការផ្គត់ផ្គង់តម្រូវការប្រចាំថ្ងៃ ទីផ្សារផលិតផលកសិកម្ម ការកែលម្អដីធ្លី និងបច្ចេកទេសកសិកម្ម) និងបំណងប្រាថ្នាតាមរយៈការធ្វើជាម្ចាស់រួមគ្នានិងគ្រប់គ្រងសហគ្រាសជាលក្ខណៈប្រជាធិបតេយ្យ។

## ចរិតលក្ខណៈរបស់សហគមន៍កសិកម្ម

ខាងក្រោមនេះគឺជាចរិតលក្ខណៈរបស់សហគមន៍កសិកម្ម៖

ក) សហគមន៍កសិកម្ម មានលក្ខណៈស្វយ័ត។ វាជាអង្គភាពឯករាជ្យដាច់ដោយឡែកពីរដ្ឋាភិបាល ក្រុមហ៊ុនឯកជន និងបក្សនយោបាយ។ គ្មានអ្នកណា ក្រៅពីសមាជិក អាចជ្រៀតជ្រែកនិងត្រួតត្រាការគ្រប់គ្រងនិងប្រតិបត្តិការរបស់សហគមន៍កសិកម្មបានឡើយ ។ មានតែសមាជិកពេញសិទ្ធិទេដែលអាចមានសិទ្ធិធ្វើបែបនេះបាន។ ទោះជាយ៉ាងណាសហគមន៍កសិកម្ម គួរតែរក្សាទំនាក់ទំនងល្អជាមួយរដ្ឋាភិបាល ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ខ) សហគមន៍កសិកម្ម គឺជាសមាគមមនុស្ស (កសិករ អ្នកជួលដី កសិករគ្មានដី អ្នកកែច្នៃផលិតផលកសិកម្ម កសិករផលិតទឹកដោះគោ អ្នកដាំផ្លែឈើ និងសមាជិកនៅក្នុងស្រុក ក្រុង សហគមន) ។

សហគមន៍កសិកម្ម អាចទទួលជាសមាជិកសហគមន៍បានចំពោះបុគ្គលដែលមានដី ឬធ្វើការនៅលើដីដែលជួលពីគេ និងពាក់ព័ន្ធនឹងការកែច្នៃទំនិញកសិកម្ម ការស្តុកទំនិញ និងការដឹកជញ្ជូន។ អ្នកដែលពាក់ព័ន្ធនឹងការផលិតនិងការចែកចាយបន្លែ ផ្លែឈើ គ្រឿងឧបភោគបរិភោគ សាច់គោ និងទឹកដោះគោ បក្សាបក្សី សាច់ជ្រូកជាដើម អាចត្រូវបានអនុញ្ញាតឱ្យក្លាយជាសមាជិកសហគមន៍កសិកម្មបាន។ មានតែសមាជិកដែលបានបង់ប្រាក់សមាជិកភាព និងទិញភាគហ៊ុនមួយយ៉ាងតិចពីសហគមន៍កសិកម្មនោះទេ ដែលមានសិទ្ធិក្នុងការបោះឆ្នោត។

គ) សមាជិករបស់សហគមន៍នៅតាមតំបន់ មានសិទ្ធិក្នុងការចូលរួមសហគមន៍កសិកម្មដោយសេរីនិងលាឈប់ពីសមាជិកភាពនៅពេលដែលពួកគេចង់ចាកចេញ។ ការចូលរួមនៅក្នុងសហគមន៍កសិកម្ម គឺជាការស្ម័គ្រចិត្ត មិនមានកសិកររូបណា ដែលត្រូវបានដាក់សំពាធបង្ខំ ដើម្បីបានក្លាយជាសមាជិករបស់សហគមន៍កសិកម្មនោះទេ វាគឺជាការស្ម័គ្រចិត្តនិងជាជម្រើស។ សមាជិក មានសិទ្ធិក្នុងការចាកចេញពីសហគមន៍កសិកម្មដោយសេរី ។ មិនមានសមាជិករូបណា ដែលអាចត្រូវបានបណ្តេញចេញពីសមាជិកភាព លើកលែងតែមានចែងនៅក្នុងលក្ខន្តិកៈរបស់សហគមន៍កសិកម្ម។

ឃ) សមាជិកសហគមន៍កសិកម្ម មានការពេញចិត្តនឹងការបំពេញតម្រូវការសេដ្ឋកិច្ច សង្គម និងវប្បធម៌ តាមរយៈសហគមន៍កសិកម្មរបស់ពួកគេ ដូចជាជី គ្រាប់ពូជ ឧបករណ៍កែលម្អដី ការច្រូតកាត់និងការស្តុកទំនិញរួមទាំងការដឹកជញ្ជូន។ សហគមន៍កសិកម្ម ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការគាំទ្រដល់កសិករដែលជាសមាជិក។ សហគមន៍កសិកម្ម ផ្តល់ផលប្រយោជន៍ដល់សមាជិក និងរួមចំណែកក្នុងការគាំទ្រដល់សហគមន៍រស់នៅរបស់ពួកគេហើយកសិករដែលជាសមាជិក អាចស្នើសុំសហគមន៍កសិកម្មក្នុងការផ្តល់សេវាកម្មផ្សេងៗ។ សេវាកម្មទាំងអស់ គឺត្រូវតែបង់ប្រាក់។ មិនមានអ្វីផ្តល់ឱ្យដោយមិនយកកំរៃនៅក្នុងសហគមន៍កសិកម្មដូចនៅក្នុងអង្គការរដ្ឋាភិបាលនោះទេ។

សហគមន៍កសិកម្មអាចផ្តល់សេវាកម្មចំបងចំនួនប្រាំដល់សមាជិកដូចជា ឥណទាន (សន្សំនិងកម្ចី) ទីផ្សារ ផ្គត់ផ្គង់ធាតុចូលកសិកម្មនិងការផ្គត់ផ្គង់តម្រូវការចាំបាច់ប្រចាំថ្ងៃ សេវាប្រើប្រាស់ឧបករណ៍កសិកម្ម ឬសំភារៈរួមគ្នា និងការផ្តល់ដំបូន្មានបច្ចេកទេសកសិកម្ម។

ង) សហគមន៍កសិកម្ម គឺជាសហគ្រាសដែលរួមគ្នាធ្វើជាម្ចាស់និងគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យ។ កសិករដែលជាសមាជិក គឺជាម្ចាស់ អ្នកត្រួតពិនិត្យ អ្នកគ្រប់គ្រង និងជាអ្នកប្រើប្រាស់របស់សហគមន៍កសិកម្មរបស់ពួកគេ។ ការគ្រប់គ្រងគឺផ្អែកទៅលើគោលការណ៍គ្រប់គ្រងបែបប្រជាធិបតេយ្យ តម្លាភាព និងគណនេយ្យភាព។ សហគមន៍កសិកម្ម មានស្ថានភាពតែមួយគត់ គឺ

ថាផ្តល់សេវាកម្មសេដ្ឋកិច្ចនិងសង្គមដល់សមាជិក ។ លក្ខណៈនេះគឺមិនមាននៅក្នុងទំរង់អាជីវកម្មរដ្ឋ និងឯកជនឡើយ។

## គោលការណ៍គ្រឹះរបស់សហគមន៍/សហករណ៍

សហគមន៍កសិកម្មទាំងអស់នៅទូទាំងពិភពលោក ត្រូវបានអនុវត្តតាមគោលការណ៍សហគមន៍ដែលជាមូលដ្ឋានទទួលស្គាល់ជាសកល។ គោលការណ៍សហគមន៍មានចំនួនប្រាំពីរដូចខាងក្រោម៖

***គោលការណ៍គ្រឹះទី១៖ ការចូលរួមដោយស្ម័គ្រចិត្តនិងបើកចំហសមាជិកភាព៖*** សហគមន៍ ត្រូវបានបង្កើតឡើងតាមលក្ខណៈស្ម័គ្រចិត្ត បើកចំហចំពោះមនុស្សទាំងអស់ដើម្បីប្រើប្រាស់សេវាកម្មនិងសុខចិត្តទទួលខុសត្រូវចំពោះសមាជិកភាពដោយមិនរើសអើងចំពោះយេនឌ័រ សង្គម ពូជសាសន៍ នយោបាយ និងសាសនាឡើយ។

***គោលការណ៍គ្រឹះទី២៖ ការគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យដោយសមាជិក៖*** សហគមន៍ត្រូវដឹកនាំនិងគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ ដោយសមាជិកដែលបានចូលរួមក្នុងការកំណត់គោលនយោបាយនិងក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា។ បុរស និងស្ត្រីដែលត្រូវបានបោះឆ្នោតជាប់ក្នុងរចនាសម្ព័ន្ធដឹកនាំត្រូវតែមានគណនេយ្យភាពចំពោះសមាជិក។ សមាជិករបស់សហគមន៍កសិកម្មមានសិទ្ធិបោះឆ្នោត ស្មើភាពគ្នាគឺសមាជិកម្នាក់មានសំឡេងឆ្នោតមួយ ហើយសហគមន៍នៅកំរិតផ្សេងទៀត ក៏ត្រូវបានបង្កើតឡើងតាមបែបប្រជាធិបតេយ្យផងដែរ។

***គោលការណ៍គ្រឹះទី៣៖ ការចូលរួមផ្នែកសេដ្ឋកិច្ចរបស់សមាជិក៖*** សមាជិកទាំងអស់ត្រូវចូលរួមដើមទុនដល់សហគមន៍ដោយលក្ខណៈសមភាព និងត្រូវគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យ។ មួយចំណែកនៃដើមទុនរបស់សមាជិក ត្រូវក្លាយជាទ្រព្យសម្បត្តិរួមរបស់សហគមន៍។ សមាជិកទទួលបានប្រាក់ភាគលាភមានកំណត់ បើសិនជាមាន ទៅលើដើមទុនដែលបានចូលរួមក្នុងលក្ខខណ្ឌជាសមាជិក (ប្រាក់ភាគលាភមានកំណត់)។

សមាជិកសហគមន៍ ត្រូវបែងចែកប្រាក់ចំណេញខ្លះឬទាំងអស់ដើម្បី(ក) អភិវឌ្ឍសហគមន៍កសិកម្មនិងត្រូវបង្កើតមូលនិធិបម្រុង (ខ) បែងចែកជាប្រាក់លើកទឹកចិត្តដល់សមាជិកសហគមន៍ដោយផ្អែកតាមសមាមាត្រសកម្មភាពធ្វើជំនួញរបស់គេជាមួយសហគមន៍ និង (គ) គាំទ្រសកម្មភាពផ្សេងៗទៀតដែលត្រូវសម្រេចដោយសមាជិកសហគមន៍តាមរយៈមហាសន្និបាត។

***គោលការណ៍គ្រឹះទី៤៖ ស្វ័យភាពនិងឯករាជ្យ៖*** សហគមន៍ ត្រូវមានលក្ខណៈស្វយ័ត ជួយខ្លួនឯង និង គ្រប់គ្រងដោយសមាជិក។ ប្រសិនបើសហគមន៍មានកិច្ចព្រមព្រៀង ឬកិច្ចសន្យាណាមួយជាមួយស្ថាប័ន ពាក់ព័ន្ធរួមមានរាជរដ្ឋាភិបាល ឬការទទួលបានហិរញ្ញវត្ថុពីប្រភពខាងក្រៅ សហគមន៍អាចធ្វើបាននៅក្នុង លក្ខខណ្ឌដែលអាចធានាបាននូវការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យដោយសមាជិក និងរក្សាបាននូវ ស្វ័យភាពរបស់ខ្លួន។

***គោលការណ៍គ្រឹះទី៥៖ ការអប់រំ ការបណ្តុះបណ្តាល និងការផ្តល់ព័ត៌មាន៖*** សហគមន៍ ត្រូវផ្តល់ការអប់រំនិ ងការបណ្តុះបណ្តាលទៅដល់សមាជិករបស់ខ្លួនដល់អ្នកតំណាងដែលបានជាប់ឆ្នោត និងបុគ្គលិកដើម្បី ធ្វើឲ្យគេអាចចូលរួមយ៉ាងសកម្ម និងមានប្រសិទ្ធភាពក្នុងការអភិវឌ្ឍសហគមន៍របស់ខ្លួននិងធ្វើឲ្យពួកគេ អាចផ្សព្វផ្សាយជាសាធារណៈ ជាពិសេសដល់ក្រុមយុវជននិងអ្នកមានគំនិតជាអ្នកដឹកនាំអំពីកម្មវត្ថុនិង ផលប្រយោជន៍របស់សហគមន៍។

***គោលការណ៍គ្រឹះទី៦៖ ការធ្វើកិច្ចសហប្រតិបត្តិការជាមួយសហគមន៍កសិកម្មផ្សេងទៀត៖*** សហគមន៍ ត្រូវ បម្រើសមាជិករបស់ខ្លួនឲ្យមានប្រសិទ្ធភាពខ្ពស់ និងត្រូវពង្រឹងខ្លួនតាមរយៈការធ្វើការរួមគ្នាជារចនាសម្ព័ន្ធនៅ ថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។

***គោលការណ៍គ្រឹះទី៧៖ ការគិតគូរដល់សហគមន៍៖*** សហគមន៍ ត្រូវគិតគូរដល់ប្រយោជន៍រួម ធ្វើយ៉ាងណា ឲ្យមានការអភិវឌ្ឍសហគមន៍ ប្រកបដោយចីរភាពស្របតាមគោលបំណងនិងទិសដៅរបស់សមាជិកសហ គមន៍។

ជាអកុសល គោលការណ៍ទី៣ មិនបានបញ្ជ្រាបពេញលេញទៅក្នុងផ្នត់គំនិត សមាជិកនិងថ្នាក់ដឹកនាំរបស់ សហគមន៍កសិកម្មនៅក្នុងប្រទេសកម្ពុជានៅឡើយទេ។ ពួកគេភាគច្រើន បានយល់ច្រឡំពីគោលបំណង សំខាន់របស់សហគមន៍កសិកម្មទាក់ទងនឹងការផ្តល់ជូនប្រាក់ភាគលាភដល់សមាជិក។ សហគមន៍កសិកម្ម បានផ្តល់ប្រាក់ភាគលាភច្រើនដល់សមាជិក ដើម្បីបង្កើនចំនួនសមាជិកនៅក្នុងសហគមន៍កសិកម្មរបស់ខ្លួន។

ថ្នាក់ដឹកនាំសហគមន៍កសិកម្មនៅក្នុងប្រទេសកម្ពុជាត្រូវយល់អោយច្បាស់ពីគោលការណ៍គ្រឹះទី៣ "ការ កំណត់ប្រាក់ភាគលាភ" និង "បែងចែកប្រាក់ចំណេញសម្រាប់អភិវឌ្ឍន៍សហគមន៍" និងសារៈតារ ហើយត្រូវ ពន្យល់សមាជិកសហគមន៍កសិកម្មដើម្បីលុបបំបាត់ការយល់ច្រលំរបស់ពួកគេ ។

សមាជិកសហគមន៍កសិកម្មនៅក្នុងប្រទេសកម្ពុជាភាគច្រើន បានចូលរួមនៅក្នុងសហគមន៍កសិកម្មដើម្បី ទទួលបាននូវប្រាក់ភាគលាភនិងរំពឹងថាបានប្រាក់ចំណេញខ្ពស់។ វាពិតជាពិបាកសម្រាប់ថ្នាក់ដឹកនាំសហ

គមន៍កសិកម្មក្នុងការបញ្ចុះបញ្ចូលសមាជិកទាំងនោះឱ្យទទួលយកនូវប្រាក់ភាគលាភទាប ប៉ុន្តែពួកគេគួរតែត្រូវធ្វើបែបនេះហើយមន្ត្រីអភិវឌ្ឍន៍សហគមន៍កសិកម្ម ក៏គួរតែគាំទ្រពេញទំហឹងចំពោះសកម្មភាពមួយនេះ បើមិនដូច្នោះទេសហគមន៍កសិកម្មពិបាកបង្កើនដើមទុននិងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួនណាស់។

## តម្លៃមូលដ្ឋាន និងតម្លៃសីលធម៌របស់សហគមន៍កសិកម្ម

គោលការណ៍សហគមន៍/សហករណ៍ គឺផ្អែកលើមូលដ្ឋានសហគមន៍និងតម្លៃក្រមសីលធម៌ រួមមាន (ក) តម្លៃនៃការជួយខ្លួនឯង ភាពមានទំនួលខុសត្រូវ ប្រជាធិបតេយ្យ សមភាព សមធម៌និងសាមគ្គីភាព ហើយ (ខ) តម្លៃក្រមសីលធម៌គឺ ភាពស្មោះត្រង់ បើកចំហរ ទំនួលខុសត្រូវចំពោះសង្គម និងការយកចិត្តទុកដាក់ចំពោះអ្នកដទៃ។

---

# ជំពូកទី២

## រចនាសម្ព័ន្ធនិងការគ្រប់គ្រងរបស់សហគមន៍កសិកម្ម



ឥទ្ធិពលពិតប្រាកដរបស់សហគមន៍កសិកម្ម គឺនៅក្នុងសហគមន៍រស់នៅដែលទីកន្លែងសមាជិកចូលរួមសហគមន៍។ សមាជិកស្របច្បាប់ ដែលបានបង់ប្រាក់សមាជិកភាពនិងទិញភាគហ៊ុនយ៉ាងតិចមួយហ៊ុនមានសិទ្ធិបង្ហាញពីតម្រូវការរបស់សហគមន៍រស់នៅ។ សមាជិកជាអ្នករៀបចំមហាសន្និបាត។ មហាសន្និបាតបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលដែលរួមមានប្រធាន អនុប្រធាន និងសមាជិក។ ក្រុមប្រឹក្សាភិបាលគឺជាអង្គភាពគ្រប់គ្រងសហគមន៍កសិកម្ម។ ផ្អែកលើគោលនយោបាយសម្រេចដោយមហាសន្និបាតក្រុមប្រឹក្សាភិបាល អនុវត្តតាមសេចក្តីសម្រេចតាមរយៈបុគ្គលិកគ្រប់គ្រងដែលមានជំនាញ។

គណៈកម្មាធិការត្រួតពិនិត្យ ដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយមហាសន្និបាតត្រូវធ្វើការត្រួតពិនិត្យសេចក្តីសម្រេចនិងសកម្មភាពរបស់ក្រុមប្រឹក្សាភិបាល។ ហេតុដូច្នេះ សហគមន៍កសិកម្មមានអង្គភាពសំខាន់ចំនួន៤ គឺមហាសន្និបាត ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការត្រួតពិនិត្យ និងបុគ្គលិកគ្រប់គ្រង។

---

# ជំពូកទី៣

## លក្ខន្តិកៈរបស់សហគមន៍កសិកម្ម

**លក្ខន្តិកៈ**

លក្ខន្តិកៈរបស់សហគមន៍កសិកម្ម ត្រូវបានអនុម័តដោយសមាជិកតាមការស្ម័គ្រចិត្ត។ វាប្រៀបដូចជាមគ្គុទេសក៏ក្នុងការគ្រប់គ្រងសម្រាប់មន្ត្រីទាំងអស់នៅក្នុងសហគមន៍កសិកម្ម។ លក្ខន្តិកៈគំរូថតចម្លងមួយច្បាប់ ត្រូវបានប្រគល់ជូនអ្នកបង្កើតសហគមន៍ដោយអង្គភាពចុះបញ្ជីសហគមន៍កសិកម្ម។

សមាជិកអាចធ្វើការផ្លាស់ប្តូរនិងអនុម័តលក្ខន្តិកៈទៅតាមស្ថានភាពជាក់ស្តែងរបស់ខ្លួន ។ បន្ទាប់មក ត្រូវបានចុះបញ្ជីដោយអង្គភាពចុះបញ្ជី ។ វាផ្តល់ភាពស្រប ច្បាប់ទៅដល់ឯកសារនិងសហគមន៍កសិកម្ម។ មហាសន្និបាត មានសិទ្ធិក្នុងការផ្លាស់ប្តូរ (កែប្រែ)បទបញ្ញត្តិនៅក្នុងលក្ខន្តិកៈ។ និទ្ទេសរបស់លក្ខន្តិកៈ ដែលត្រូវបានរៀបរាប់នៅក្នុងច្បាប់ស្តីពីសហគមន៍កសិកម្មឆ្នាំ២០១៣ របស់ប្រទេសកម្ពុជា មានដូចខាងក្រោម៖

- នាមករណ៍
- ស្លាកសញ្ញា ទីស្នាក់ការ និងអាសយដ្ឋាន

- ដើមទុនដែលបានមកពីភាគហ៊ុន តម្លៃភាគហ៊ុន និងលក្ខខណ្ឌនៃការបង់ភាគហ៊ុន
- លក្ខខណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុ
- របៀបរបបនៃការចុះបញ្ជីគណនេយ្យនិងការគ្រប់គ្រងឯកសារនានា
- ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់សមាជិកចំពោះបំណុលរបស់សហគមន៍កសិកម្ម។ ការទទួលខុសត្រូវនេះមិនត្រូវមានកម្រិតលើសពី៤(បួន)ដងនៃចំនួនភាគហ៊ុនដែលសមាជិកម្នាក់ៗកាន់កាប់ឡើយ
- សិទ្ធិនិងកាតព្វកិច្ចរបស់សមាជិក
- លក្ខខណ្ឌនៃការសុំចូលជាសមាជិក
- លក្ខខណ្ឌនៃការលាឈប់និងការបណ្តេញចេញពីសមាជិកភាពសហគមន៍កសិកម្ម
- ការប្រព្រឹត្តទៅរបស់មហាសន្និបាតនិងមហាសន្និបាតតំណាង
- សមាសភាពក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ
- លក្ខខណ្ឌនៃការកោះប្រជុំក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ
- តួនាទីនិងភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ
- លក្ខខណ្ឌនៃការបញ្ចូលគ្នារបស់សហគមន៍កសិកម្ម
- លក្ខខណ្ឌនៃការរំលាយសហគមន៍កសិកម្ម
- នីតិវិធីដោះស្រាយវិវាទនៅក្នុងសហគមន៍កសិកម្ម
- នីតិវិធីនៃការកែប្រែឬវិសោធនកម្មលក្ខន្តិកៈ

កំណែទំរង់ចុងក្រោយនៃលក្ខន្តិកៈ ត្រូវបានរក្សាទុកនៅក្នុងការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្មនិងនាយកដ្ឋានអភិវឌ្ឍសហគមន៍កសិកម្ម។ វាបើកចំហរ និងអាចប្រើប្រាស់បានសម្រាប់សមាជិកគ្រប់ពេលវេលា។ វាគឺជាមគ្គុទេស និងក្រមប្រតិបត្តិការងារសម្រាប់អ្នកកាន់តួនាទីផ្សេងៗគ្នារបស់សហគមន៍កសិកម្ម។ មិនមានសេចក្តីសម្រេចណាដែលអាចប្រឆាំងនឹងបទបញ្ញត្តិរបស់លក្ខន្តិកៈបានឡើយ។

---

# ជំពូកទី៤
# មហាសន្និបាតនៅក្នុងសហគមន៍កសិកម្ម

តួនាទីនៃមហាសន្និបាតនៅក្នុងសហគមន៍កសិកម្ម គឺមានសារៈសំខាន់ណាស់។ សហគមន៍កសិកម្ម អាចឆ្លើយតបទៅនឹងតម្រូវការរបស់សមាជិកបានតាមរយៈកិច្ចប្រជុំមហាសន្និបាត។ សហគមន៍កសិកម្ម គឺជាស្ថាប័នប្រកបមុខរបរនិងផ្តល់សេវាកម្មដែលមានភាពរីកចម្រើន។ មហាសន្និបាត គឺជាអង្គការកំពូលរបស់សហគមន៍ដែលប្រកបរបរកសិកម្ម។

ការគ្រប់គ្រងរបស់សហគមន៍កសិកម្ម មានមហាសន្និបាតច្រើនប្រភេទដូចខាងក្រោម៖

## ១) មហាសន្និបាតប្រចាំឆ្នាំរបស់សមាជិក

មហាសន្និបាតប្រចាំឆ្នាំ គឺជាអង្គការខ្ពស់បំផុតនិងមានអំណាចរបស់សហគមន៍កសិកម្ម។ មហាសន្និបាតប្រចាំឆ្នាំត្រូវបានធ្វើឡើងម្តងសម្រាប់រយៈពេលមួយឆ្នាំ ដើម្បីកត់សម្គាល់នូវដំណើរការសកម្មភាពសេចក្តីសម្រេចចំពោះការចំណាយ និងអនុម័តផែនការសកម្មភាពនិងផែនការថវិកា។ មហាសន្និបាត ត្រូវបានធ្វើឡើងដើម្បីបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាលគណៈកម្មាធិការត្រួតពិនិត្យ និងគណៈកម្មាធិការផ្សេងៗ។

## ២) មហាសន្និបាតវិសាមញ្ញរបស់សមាជិក

មហាសន្និបាតវិសាមញ្ញត្រូវបានធ្វើឡើងស្របតាមតម្រូវការរបស់សមាជិក ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យ ដើម្បីដោះស្រាយបញ្ហាបន្ទាន់របស់សហគមន៍កសិកម្ម។

## ៣) កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ត្រូវបានបោះឆ្នោតជ្រើសរើសដោយមហាសន្និបាត។ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវបានធ្វើឡើងជាទៀងទាត់ និងជាទូទៅមួយខែម្តង។ កិច្ចប្រជុំនេះ ត្រូវបានធ្វើឡើងដើម្បីធ្វើសេចក្តីសម្រេចទៅលើប្រាក់កម្ចីដែលផ្តល់ឱ្យសមាជិក និងគ្រប់គ្រងចំណូលនិងចំណាយរបស់សហគមន៍។ ក្រុមប្រឹក្សាភិបាលគឺត្រូវទទួលខុសត្រូវចំពោះកិច្ចប្រជុំមហាសន្និបាត។

## ៤)កិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យ

សមាជិកគណៈកម្មាធិការត្រួតពិនិត្យ ត្រូវបានបោះឆ្នោតជ្រើសរើសដោយកិច្ចប្រជុំមហាសន្និបាត។ កិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យ ត្រូវបានធ្វើឡើងតាមការកោះហៅរបស់ប្រធានគណៈកម្មាធិការត្រួតពិនិត្យឬដោយការស្នើសុំរបស់សមាជិក។ គោលបំណង គឺដើម្បីត្រួតពិនិត្យសកម្មភាពរបស់ក្រុមប្រឹក្សាភិបាល ក្នុងការធានាគណនេយ្យភាពជូនសមាជិកសហគមន៍កសិកម្ម។ គណៈកម្មាធិការត្រួតពិនិត្យ ត្រូវរាយការណ៍ពីលទ្ធផលនៃការត្រួតពិនិត្យជូនអង្គប្រជុំមហាសន្និបាត។

## ៥) កិច្ចប្រជុំផ្សេងៗ

មហាសន្និបាត អាចបោះឆ្នោតជ្រើសរើស ឬតែងតាំងគណៈកម្មាធិការនានា។ គណៈកម្មាធិការទាំងនេះត្រូវធ្វើរបាយការណ៍ជូនមហាសន្និបាត។ កិច្ចប្រជុំរបស់គណៈកម្មាធិការទាំងនេះអាចធ្វើឡើងនៅពេលដែលចាំបាច់។

---

# ជំពូកទី៥

# ប្រភពធនធាននិងប្រាក់ចេញរបស់សហគមន៍កសិកម្ម

ប្រភពធនធានរបស់សហគមន៍កសិកម្ម បានមកពីប្រភពខាងក្រោមៈ

១) ប្រាក់សមាជិកភាព
២) ភាគហ៊ុនដែលទិញដោយសមាជិក
៣) ការប្រាក់ទទួលបានពីការផ្តល់ប្រាក់កម្ចីដល់សមាជិក
៤) កម្រៃជើងសារឬសេវាកម្មរបស់ទីភ្នាក់ងារទៅលើការលក់ផលិតផលរបស់សមាជិក
៥) បញ្ញើសន្សំ (ចាំបាច់និងឬជំរើស)របស់សមាជិក
៦) ប្រាក់កម្ចីពីប្រភពខាងក្រៅរបស់សហគមន៍កសិកម្ម
៧)ប្រាក់បង់សេវាកម្មដែលប្រើប្រាស់ដោយសមាជិក
៨) ការប្រាក់ដែលទទួលបានពីបញ្ញើសន្សំនៅក្នុងធនាគារ
៩) ប្រាក់ដែលពិន័យដោយសហគមន៍កសិកម្ម
១០) វិភាគទាននិងអំណោយ

គ្រប់មូលនិធិដែលចូលមកសហគមន៍កសិកម្ម គឺត្រូវបានទទួលដោយគណនេយ្យកររបស់សហគមន៍កសិកម្ម និងត្រូវបានដាក់បញ្ញើនៅក្នុងធនាគារដើម្បីសុវត្ថិភាព។ សាច់ប្រាក់ខ្លះ អាចត្រូវបានរក្សាទុកនៅក្នុងសហគមន៍កសិកម្មដើម្បីឆ្លើយតបនឹងការចំណាយនិងផ្តល់ឲសមាជិកខ្ចីរៀងរាល់ថ្ងៃ ។

ខាងក្រោមគឺជាសាច់ប្រាក់ចេញពីសហគមន៍កសិកម្មដែលត្រូវបានរាប់បញ្ចូលៈ

១) ប្រាក់ខែរបស់នាយកប្រតិបត្តិ ឬបុគ្គលិក
២) ប្រាក់កម្ចីដែលផ្តល់ឱ្យសមាជិក
៣) ថ្លៃជួលសម្ភារៈនិងបុគ្គលិកដែលត្រូវបង់ដោយសហគមន៍កសិកកម្ម
៥) ការចំណាយលើការគ្រប់គ្រងការិយាល័យដែលរួមមានសម្ភារៈការិយាល័យ គ្រឿងសង្ហារឹម និងគ្រឿងបរិក្ខារផ្សេងៗ
៥) ចំណាយលើការធ្វើដំណើរ
៦) ចំណាយលើប្រតិបត្តិការដូចជាការជួសជុល ប្រេង អគ្គិសនីជាដើម
៧) ចំណាយស្របច្បាប់និងការប្រឹក្សាយោបល់
៨)ប្រៃសណីយ៍និងទូរគមនាគមន៍
៩) ធានារ៉ាប់រ៉ង និងការផ្គត់ផ្គង់
១០) សាច់ប្រាក់ទិញទំនិញសំរាប់លក់
១១) ចំណាយផ្សេងៗទៀត

របាយការណ៍គណនីដែលបង្ហាញពីចំណូល និងចំណាយត្រូវបានរៀបចំយ៉ាងទៀងទាត់ដោយក្រុមប្រឹក្សាភិបាលរបស់សហគមន៍កសិកម្ម។ ជាមូលដ្ឋានទូទៅ សាច់ប្រាក់នៅក្នុងដៃនិងរបាយការណ៍ធនាគារ គឺត្រូវបានសម្របសម្រួលដើម្បីឱ្យមានភាពត្រឹមត្រូវ។ រាល់ចំណាយនិងសាច់ប្រាក់ចេញទាំងអស់ ត្រូវបានសម្រេចដោយក្រុមប្រឹក្សាភិបាលរៀងរាល់ពេល។

-----------------------------------------------------------------------------

# ជំពូកទី៦

## មុខរបររបស់សហគមន៍កសិកម្ម




យោងតាមកំរិតនៃការប្រតិបត្តិការមុខរបរ សហគមន៍កសិកម្ម អាចពង្រីកមុខរបររបស់ខ្លួនដល់សមាជិក។ ការពង្រីកមុខរបរ គឺសំដៅលើការផ្តល់ឧបករណ៍កសិកម្ម ការសង់ឃ្លាំង ការផ្តល់ទីផ្សារ ការផ្តល់ឧបករណ៍ដឹកជញ្ជូនម៉ាស៊ីនកែច្នៃកសិកម្មនិងសេវាកម្មផ្តល់ដំបូន្មានគ្រប់ប្រភេទដល់សមាជិក។ សហគមន៍កសិកម្មប្រកបមុខរបរនៅពេលមានតម្រូវការពីសមាជិក។ តម្រូវការរបស់សមាជិក ត្រូវបានកំណត់ដោយសហគមន៍តាមរយៈកិច្ចប្រជុំនិងទំនាក់ទំនងផ្ទាល់ខ្លួន។

-----------------------------------------------------------------

# ផ្នែកទី១៖ មុខរបរឥណទានសហគមន៍កសិកម្ម

សហគមន៍កសិកម្ម ដោះស្រាយនូវតម្រូវការបច្ចេកទេសនិងតម្រូវការផ្ទាល់ខ្លួនរបស់សមាជិក។ សហគមន៍ផ្តល់ធាតុចូលកសិកម្មគ្រប់ប្រភេទនិងតម្រូវការចាំបាច់ប្រចាំថ្ងៃ។ សហគមន៍កសិកម្ម ស្វែងរកទីផ្សារសម្រាប់ផលិតផលរបស់សមាជិក។ មុខរបរឥណទាន សម្រាប់ផ្តល់ប្រាក់កម្ចីដល់សមាជិកនិងទទួលប្រាក់បញ្ញើសន្សំពីសមាជិក ។

ប្រាក់កម្ចីដែលត្រូវបានផ្តល់ដោយសហគមន៍កសិកម្ម មានច្រើនប្រភេទ។ ប្រភេទប្រាក់កម្ចីទាំងនេះមានដូចជា ប្រាក់កម្ចីរយៈពេលវែង និងប្រាក់កម្ចីរយៈពេលខ្លី (ឬមធ្យម)។ ប្រាក់កម្ចីរយៈវែង គឺសម្រាប់កែលម្អដីធ្លី ជារាសាស្រ្ត និងដើម្បីបង្កើតសម្ភារៈសម្រាប់ផលិតកម្មកសិកម្ម។ ប្រាក់កម្ចីរយៈពេលខ្លី គឺដើម្បីធ្វើផលិតកម្មកសិកម្ម ដូចជាសម្រាប់ដាំដំណាំតាមរដូវកាល។ ប្រាក់កម្ចីនេះ គឺមានតម្រូវការខ្ពស់និងត្រូវបានផ្តល់ដោយផ្អែកលើរដូវកាលដាំដំណាំ។ ប្រាក់កម្ចីនេះ ត្រូវបានផ្តល់ក្នុងអត្រាការប្រាក់សមរម្យ (ដែលទាបជាងអត្រាការប្រាក់នៅក្នុងទីផ្សារសេរី)។

រាល់ប្រាក់កម្ចីទាំងអស់និងប្រតិបត្តិការមុខរបរ ត្រូវបានពិភាក្សានិងសម្រេចដោយគណៈកម្មាធិការផ្សេងៗនិងក្រុមប្រឹក្សាភិបាល។

ប្រាក់កម្ចី ត្រូវបានផ្តល់ដល់សមាជិក ដោយយោងទៅតាមដែនកំណត់នៃប្រាក់កម្ចីដែលកំណត់ដោយសហគមន៍កសិកម្ម។

រាល់ប្រាក់កម្ចីទាំងអស់ មិនគួរប្រើដើមទុនដែលជាភាគហ៊ុនរបស់សហគមន៍កសិកម្មឡើយ។ បើសិនសហគមន៍មិនមានដើមទុនគ្រប់គ្រាន់ សហគមន៍អាចខ្ចីប្រាក់ពីសហគមន៍ដទៃទៀត ធនាគារសហគមន៍ធនាគារ ឬរដ្ឋាភិបាល ដើម្បីផ្តល់ប្រាក់កម្ចីដល់សមាជិក។ ជាទូទៅសហគមន៍កសិកម្ម ត្រូវកំណត់ប្រាក់កម្ចីអតិបរមាពីខាងក្រៅ។

សមាជិក ជាទូទៅមានសិទ្ធិទទួលបានឥណទានពីរឬបីដងនៃចំនួនភាគហ៊ុនដែលពួកគេបានទិញ ដោយយោងតាមបទបញ្ជាផ្ទៃក្នុង។ រាល់ប្រាក់កម្ចីទាំងអស់ត្រូវបានផ្តល់ឱ្យសមាជិកដោយការប្រាក់។ អត្រាការប្រាក់ គឺត្រូវបានកំណត់ដោយបទបញ្ជាផ្ទៃក្នុង។ អត្រាការប្រាក់ជាទូទៅ ទាបជាងអត្រាការប្រាក់នៅទីផ្សារសេរី។ អត្រាការប្រាក់នៅទីផ្សារសេរី គឺខ្ពស់គួរឱ្យពិចារណា។ រាល់ប្រាក់កម្ចីទាំងអស់ ត្រូវតែសងត្រលប់មកសហគមន៍កសិកម្មវិញនៅក្នុងរយៈពេលដែលបានកំណត់។

បើសិនប្រាក់កម្ចី មិនត្រូវបានសងត្រលប់ទាន់ពេលវេលានោះទេ សមាជិកដែលខ្ចីប្រាក់មិនទាន់សង នឹងត្រូវទទួលការផាកពិន័យ។ សមាជិកនោះ អាចត្រូវបានដកសិទ្ធិក្នុងការទទួលប្រាក់កម្ចី ដោយសារតែនៅមិនទាន់សងប្រាក់។

រាល់ប្រាក់កម្ចីទាំងអស់ ត្រូវតែសងត្រលប់មកសហគមន៍វិញជាមួយនឹងការប្រាក ។ ការសងប្រាក់កម្ចីទាន់ពេលវេលា គឺជួយក្នុងការផ្តល់ប្រាក់កម្ចីទៅដល់សមាជិកដទៃទៀតផងដែរ។ ដើមទុនដែលជាភាគហ៊ុនរបស់សហគមន៍កសិកម្ម គួរតែរក្សាទុកសម្រាប់ធ្វើចរាចរណ៍ដើម្បីផលប្រយោជន៍។

បើសិនជាមិនមានចរាចរណ៍ក្នុងទំរង់ជាប្រាក់កម្ចីនោះទេ សហគមន៍នឹងបាត់បង់ទំនុកចិត្តពីសមាជិក ហើយសមាជិកក៏ខកចិត្តផងដែរ។ ចរាចរណ៍ដើមទុន គឺជាកត្តាសំខាន់ដែលនាំសហគមន៍កសិកម្មឆ្ពោះទៅរកភាពជោគជ័យ។ ចរាចរណ៍ដើមទុនខ្ពស់ អាចផ្តល់លទ្ធភាពដល់សមាជិក្នុងការខ្ចីនិងទទួលបានផលប្រយោជន៍ពីសេវាកម្មឥណទាន។ ចរាចរណ៍ដើមទុនកាន់តែខ្ពស់ នឹងបង្កើតប្រាក់ចំណូលតាមរយៈការប្រាក់ ។

ស្ថានភាពនេះ អាចជួយសហគមន៍កសិកម្ម ក្នុងការទទួលបានសមាជិកបន្ថែមពីសហគមន៍រស់នៅ។ ការផ្តល់ប្រាក់កម្ចីលឿននិងអត្រាការប្រាក់ទាបសមរម្យ គឺជាកត្តាមួយសម្រាប់ទាក់ទាញសមាជិកថ្មីចូលមកសហគមន៍។ សមាជិកដែលប្រើប្រាស់សេវាឥណទានកាន់តែច្រើន មានន័យថាប្រាក់ចំណូលកាន់តែច្រើនសម្រាប់សហគមន៍កសិកម្ម (តាមរយៈការទទួលបានការប្រាក់)។

ដើម្បីទទួលបានសមាជិកកាន់តែច្រើន សហគមន៍កសិកម្ម ត្រូវតែអភិវឌ្ឍន៍ប្រព័ន្ធផ្តល់ប្រាក់កម្ចីនិងដំណោះស្រាយចំពោះប្រាក់កម្ចី ដោយមិនប្រើការពិន័យ។ នេះមានន័យថាសហគមន៍កសិកម្ម ត្រូវបង្កើតកម្មវិធីអប់រំដល់សមាជិកទាក់ទងនឹងប្រព័ន្ធឥណទាន។ ពន្យល់សមាជិកថាសហគមន៍កសិកម្ម គឺមិនមែនជាក្លឹបផ្តល់ប្រាក់កម្ចីនោះទេ។ សហគមន៍កសិកម្ម មិនកេងប្រវ័ញ្ចសមាជិករបស់ខ្លួននោះទេ ។ ពួកគេនៅទីនោះដើម្បីជួយដល់សមាជិក។

អ្នកទាំងអស់គ្នាដែលរួមមានក្រុមប្រឹក្សាភិបាល និងអ្នកអភិវឌ្ឍសហគមន៍កសិកម្ម គួរចងចាំថា គួរតែជំរុញលើកទឹកចិត្តសហគមន៍កសិកម្មឱ្យមានការសន្សំទុកជាដើមទុន។ ដើមទុន គឺជាទ្រព្យសម្បត្តិដែលអាចត្រូវបានប្រើប្រាស់មិនត្រឹមតែផ្តល់កម្ចីនោះទេ ថែមទាំងប្រកបមុខរបរផ្សេងៗទៀត។ វាមិនគួរត្រូវបានទុកដើម្បីផ្តល់ជូនសមាជិកដោយគ្មានការប្រុងប្រយ័ត្ននោះទេ។ សេចក្តីសម្រេចក្នុងការប្រើប្រាស់ដើមទុន ត្រូវតែធ្វើឡើងអោយសមហេតុផល។ ដើមទុនដែលប្រមូលបាន គឺមិនមែនសម្រាប់តែផ្តល់ប្រាក់កម្ចីនោះទេ។

គោលការណ៍គ្រឹះទី៣ នៃគោលការណ៍គ្រឹះរបស់សម្ព័ន្ធសហករណ៍អន្តរជាតិបានចែងថា "សមាជិក ជាទូទៅទទួលបានប្រាក់ភាគលាភមានកំណត់ បើសិនជាមាន ចំពោះដើមទុនដែលបានចូលរួមក្នុងលក្ខខណ្ឌជាសមាជិកភាព។ សមាជិក បែងចែកប្រាក់ចំណេញទៅតាមគោលបំណងដូចខាងក្រោម៖ ការអភិវឌ្ឍសហគមន៍ ដោយបង្កើតជាមូលនិធិបម្រុងដែលជាផ្នែកមិនអាចបែងចែក ការផ្តល់ប្រាក់លើកទឹកចិត្តដល់សមាជិកក្នុងសមាមាត្រនៃការប្រតិបត្តិការជំនួញជាមួយសហគមន៍ និងការគាំទ្រសកម្មភាពផ្សេងៗទៀតដែលបានសម្រេចដោយសមាជិក"។

បើសិនជាសមាជិក ដាក់ប្រាក់បញ្ញើសន្សំនៅក្នុងសហគមន៍កសិកម្ម ហើយសហគមន៍កសិកម្ម ផ្តល់ជាប្រាក់កម្ចីទាំងអស់ទៅដល់សមាជិក ដូច្នេះគឺមិនមានភាពខុសគ្នានោះទេរវាងសហគមន៍កសិកម្ម និងអ្នកផ្តល់ប្រាក់កម្ចីទេ។ វាគឺជាប្រការមិនល្អទេ បើសិនជាសមាជិកក្រុមប្រឹក្សាភិបាលស្នើថាដើមទុនដែលប្រមូលបាន គួរតែត្រូវបានផ្តល់ជាប្រាក់កម្ចីទាំងអស់។ ដើមទុនដែលកៀរគរបាន គឺជាប្រភពយ៉ាងសំខាន់នៃភាពខ្លាំងនៃហិរញ្ញវត្ថុរបស់សហគមន៍កសិកម្ម ហើយគួរប្រើ តែមួយចំនួនប៉ុណ្ណោះសម្រាប់ផ្តល់ជាប្រាក់កម្ចី។

នៅក្នុងអត្ថន័យនៃសេចក្តីណែនាំនេះ រាល់ចំណូលទាំងអស់ (ប្រាក់ភាគហ៊ុន ប្រាក់បញ្ញើសន្សំ និងមូលនិធិផ្សេងៗទៀត) ត្រូវតែរក្សាទុក ហើយប្រើប្រាស់នៅក្នុងផ្លូវត្រូវ ដោយមិនត្រូវទុកសម្រាប់ជាប្រាក់កម្ចីទាំងអស់ឡើយហើយមិនទុកអ្វីសោះជាទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្មនោះទេ។

---------------------------------------------------------------------------

# ផ្នែកទី២៖ មុខរបរទីផ្សាររបស់សហគមន៍កសិកម្ម

សមាជិកខ្លះ ធ្វើផលិតកម្មកសិកម្មដូចជាផលិតដំណាំសម្រាប់ធ្វើអាហារ គ្រាប់ធញ្ញជាតិ ផ្លែឈើនិងបន្លែ ទឹកដោះគោនិងផលិតផលកសិកម្មផ្សេងៗ។ សមាជិកសហគមន៍កសិកម្មខ្លះ ចិញ្ចឹមសត្វ ផលិតសាច់ កែច្នៃផលិតផលកសិកម្ម ស្តុកទំនិញ ដឹកជញ្ជូន និងកែលម្អដីធ្លី ។ សមាជិកខ្លះ ធ្វើសកម្មភាពសិប្បកម្ម ដែលប្រើប្រាស់វត្ថុធាតុដើមមានស្រាប់នៅក្នុងតំបន់ដើម្បីបង្កើនប្រាក់ចំណូល។

សមាជិកទាំងអស់ ចង់លក់ផលិតផលបានយ៉ាងឆាប់រហ័ស ដើម្បីទទួលបានប្រាក់ក្នុងការសងប្រាក់កម្ចី និងបំពេញតម្រូវការប្រចាំថ្ងៃនិងតម្រូវការផ្ទាល់ខ្លួន។ ជាមួយនឹងការទទួលបានទីផ្សារឆាប់រហ័ស សមាជិកអាចរៀបចំផែនការនាពេលអនាគតសម្រាប់ការផលិត។ ជាមួយនឹងប្រាក់នៅក្នុងដៃ ពួកគេអាចជាវធាតុចូលកសិកម្មនិងរៀបចំដីស្រែរបស់ពួកគេ។ ពួកគេ ក៏អាចពង្រឹងឬពង្រីកសម្ភារៈជារាសាស្ត្រ។ ហេតុដូច្នេះ មុខរបរទីផ្សាររបស់សហគមន៍កសិកម្ម គួរតែមានភាពឆាប់រហ័ស ងាយស្រួលនិងអាចរកប្រាក់ចំណេញ។ ដើម្បីទទួលសម្រេចគោលបំណង សហគមន៍កសិកម្មជាមួយនឹងសមាជិកដែលជាកសិករ គួរតែខិតខំប្រឹងប្រែងស្វែងរកទីផ្សារនិងផលិតគ្រឿងឧបភោគបរិភោគដែលល្អ ដែលអាចឆ្លើយតបបានទៅនឹងតម្រូវការរបស់ទីផ្សារនិងអ្នកប្រើប្រាស់។

កសិករ ជាទូទៅទទួលបានអត្រាតម្លៃទាបសម្រាប់ផលិតផលដើមដែលមិនទាន់បានកែច្នៃ។ បើសិនជាមានការបន្ថែមទៅលើតម្លៃ មុខរបរទីផ្សារនឹងអាចរកប្រាក់ចំណូលបានច្រើ ។ មានវិធីជាច្រើន ដែលអាចបន្ថែមតម្លៃទៅលើផលិតផលដើម។ សហគមន៍កសិកម្ម អាចផ្តល់ជាការគាំទ្រនិងដំបូន្មានបច្ចេកទេសដល់សមាជិករបស់ខ្លួន ហើយប្រកបមុខបរប្រើប្រាស់រួមគ្នាសម្រាប់សមាជិក។

ឃ្លាំងស្តុកទំនិញ ការដឹកជញ្ជូនឆាប់រហ័ស និងការវេចខ្ចប់ល្អនៃផលិតផលដើម អាចនឹងបន្ថែមតម្លៃដល់ផលិតផល។

ទីផ្សារឆាប់រហ័សនិងការរកប្រាក់ចំណេញបាន ក៏បានជំរុញសមាជិកនៅក្នុងសហគមន៍រស់នៅ ឱ្យក្លាយជាសមាជិកសហគមន៍កសិកម្មបានដែរ។ អ្នករាល់គ្នា ចង់បានប្រាក់ចំណេញឆាប់ ហើយវិធីនេះអាចទៅរួចជាមួយនឹងវិធីល្អនៃមុខរបរទីផ្សារ។

---

# ផ្នែកទី៣៖ មុខរបរផ្គត់ផ្គង់របស់សហគមន៍កសិកម្ម

សមាជិកដែលជាកសិកររបស់សហគមន៍កសិកម្ម ចង់បានការផ្គត់ផ្គង់ធាតុចូលកសិកម្មដែលទាន់ពេលវេលា គ្រប់គ្រាន់និងមានតម្លៃទាប សម្រាប់រដូវកាលបន្ទាប់។ ការផ្គត់ផ្គង់ទាំងនេះមានដូចជា ដីដែលមានគុណភាពនិងគ្រប់បរិមាណ គ្រាប់ពូជដែលមានគុណភាព និងឧបករណ៍កសិកម្មដែលមានគុណភាព។ ហេតុដូច្នេះ វាមានសារៈសំខាន់ណាស់ដែលសហគមន៍កសិកម្ម ត្រូវធានាថាសមាជិក ទទួលបានធាតុចូលកសិកម្មបានទាន់ពេលវេលាហើយសេវាកម្មពាក់ព័ន្ធផ្សេងៗក្នុងតម្លៃទាបជាងទីផ្សារ។ ជាមួយនឹងឥណទាននៅក្នុងដៃនិងការផ្គត់ផ្គង់ដីនិងគ្រាប់ពូជទាន់ពេលវេលា សមាជិក អាចរៀបចំផែនការផលិតកម្មបានយ៉ាងមានប្រសិទ្ធភាពជាមុន និងអាចបំពេញតម្រូវការទីផ្សារនិងតម្រូវការផ្ទាល់ខ្លួន។

ហេតុដូច្នេះ សហគមន៍កសិកម្ម ត្រូវតែធ្វើការចរចារយ៉ាងមានប្រសិទ្ធភាពជាមុនសម្រាប់ការផ្គត់ផ្គង់ដី និងគ្រាប់ពូជដែលមានគុណភាពជាដើម។ សហគមន៍កសិកម្ម ក៏ត្រូវតែរៀបចំទីតាំងឱ្យបានធំទូលាយសម្រាប់ដាក់ធាតុចូលកសិកម្មជាដុំ ដែលជាតម្រូវការរបស់សមាជិកផ្សេងៗ។ ជាមួយនឹងព័ត៌មាននៅក្នុងដៃ សហគមន៍កសិកម្មអាចចរចារថ្លៃដើមទិញទំនិញជាមួយនឹងអ្នកផលិត និងអ្នកចែកចាយឬភ្នាក់ងារ។ សហគមន៍កសិកម្ម អាចទិញទំនិញខ្លះសម្រាប់ទុកក្នុងឃ្លាំង ដើម្បីផ្គត់ផ្គង់ដល់សមាជិកបានទាន់ពេលវេលា ។

សហគមន៍កសិកម្ម គួរខិតខំប្រឹងប្រែងដើម្បីផ្គត់ផ្គង់តម្រូវការចាំបាច់ប្រចាំថ្ងៃដូចជាអាហារ ប្រេង សាប៊ូសាំងជាដើម ដល់សមាជិក។

នៅពេលសមាជិក អាចទុកចិត្តបាននូវការផ្គត់ផ្គង់ធាតុចូលបានទាន់ពេលវេលានិងគ្រប់គ្រាន់ ពួកគេនឹងមានទំនាក់ទំនងល្អជាមួយនឹងសហគមន៍កសិកម្ម។ ពួកគេ នឹងមានអារម្មណ៍ជិតស្និទ្ធជាមួយនឹងសហគមន៍កសិកម្មផងដែរ។ ពួកគេក៏អាចជំរុញសមាជិកដទៃទៀតនៅក្នុងសហគមន៍រស់នៅ ឱ្យចូលរួមនៅក្នុងសហគមន៍កសិកម្ម។ ហេតុដូច្នេះ វានឹងមានការកើនឡើងនូវសមាជិកភាពនិងមានការរីកចម្រើនក្នុងមុខរបររបស់សហគមន៍កសិកម្ម។ ការកើនឡើងសមាជិកភាព អាចលើកកំពស់មុខរបរនិងដើមទុនរបស់សហគមន៍កសិកម្ម។

---

# ផ្នែកទី៤៖ សេវាកម្មផ្តល់ដំបូន្មានបច្ចេកទេសកសិកម្ម របស់សហគមន៍កសិកម្ម

វាពិតជាមានសារៈសំខាន់ណាស់សម្រាប់កសិករ ដែលជាសមាជិកក្នុងការយល់ដឹងអំពីបច្ចេកទេសកសិកម្ម ។ ពួកគេ ត្រូវការដំបូន្មានបច្ចេកទេសអំពីពេលវេលា ប្រភេទ និងវិធីសាស្រ្តក្នុងការធ្វើកសិកម្ម។ ពួកគេ ត្រូវការដំបូន្មានអំពីការការពារដំណាំ ទើបពួកគេអាចប្រមូលផលបានល្អ។ ការប្រមូលផលបានល្អ គឺជាហេតុនាំឱ្យមានប្រាក់ចំណូលខ្ពស់ពីកសិកម្ម។

ដំបូន្មានបច្ចេកទេសកសិកម្ម មានអត្ថន័យដូចខាងក្រោម៖ វិភាគលក្ខខណ្ឌដីនិងការជ្រើសរើសនិងការរៀបចំដីឱ្យបានល្អសម្រាប់ការធ្វើកសិកម្ម ប្រភេទកសិកម្ម វាយតម្លៃទីផ្សារនៃផលិតផលកសិកម្ម តម្រូវការធាតុចូលកសិកម្មទាំងគុណភាពនិងបរិមាណ បច្ចេកទេការពារដំណាំ វិធីសាស្រ្តក្នុងការប្រមូលផល ការស្តុកផលិតផលកសិកម្ម ការវេចខ្ចប់និងដោះស្រាយផលិតផល។ សេវាកម្មទាំងនេះ គឺត្រូវបានផ្តល់ឱ្យដោយសហគមន៍កសិកម្មតាមរយៈសេវាកម្មដំបូន្មានបច្ចេកទេសកសិកម្ម ដែលទទួលខុសត្រូវដោយទីប្រឹក្សាផ្តល់ដំបូន្មានបច្ចេកទេសកសិកម្ម។

ទីប្រឹក្សាផ្តល់ដំបូន្មានបច្ចេកទេសកសិកម្ម ផ្តល់ការអប់រំដល់សមាជិកអំពីបច្ចេកទេសក្នុងការដាំដុះនិងប្រភេទកសិកម្មដែលឆ្លើយតបតម្រូវការទីផ្សារទាន់ពេលវេលា ដើម្បីទទួលបាននូវប្រាក់ចំណូលខ្ពស់។

សេវាកម្មផ្តល់ដំបូន្មានបច្ចេកទេសកសិកម្ម ជាទូទៅត្រូវបានផ្តល់ឱ្យដោយសហគមន៍កសិកម្ម ហើយក្នុងករណីខ្លះ គឺដោយសម្ព័ន្ធសហគមន៍កសិកម្មក្រោមការសហការណ៍ជាមួយនឹងមន្រ្តីបច្ចេកទេសផ្សព្វផ្សាយកសិកម្មរបស់រដ្ឋាភិបាលនៅតាមតំបន់។ ហេតុដូច្នេះ សហគមន៍កសិកម្មបានរៀបចំ "ប៊ូកៃ (ក្រុមអ្នកផលិតដែលជាសមាជិកកសិករ) ដូចជាក្រុមអ្នកផលិតស្រូវ ក្រុមអ្នកដាំប៉េងប៉ោះ ក្រុមអ្នកដាំស្ត្របឺរីក្រុមអ្នកចិញ្ចឹមមាន់ទាជាដើម ដើម្បីរៀបចំកិច្ចប្រជុំរបស់កសិករ និងកម្មវិធីធ្វើបទបង្ហាញដើម្បីផ្តល់ព័ត៌មានអំពីផលិតកម្មកសិកម្មដែលមានគុណភាព ។ សេវាកម្មផ្តល់ដំបូន្មានបច្ចេកទេសកសិកម្ម គួរតែមានទំនាក់ទំនងខ្លាំងជាមួយមុខរបរទីផ្សារនិងមុខរបរផ្គត់ផ្គង់ធាតុចូលកសិកម្មរបស់សហគមន៍កសិកម្ម និង ជាវិធីដើម្បីពង្រឹងសហគមន៍កសិកម្ម។ បើសិនកម្មវិធីនេះ ត្រូវបានរៀបចំជាទៀងទាត់ កម្មវិធីនេះនឹងទាក់ទាញសមាជិកដទៃទៀតនៅក្នុងសហគមន៍រស់នៅឱ្យក្លាយជាសមាជិកសហគមន៍កសិកម្ម។ដំបូន្មានបច្ចេកទេសកសិកម្ម គួរតែក្លាយជាសេវាកម្មដែលត្រូវបានផ្តល់ជាទៀងទាត់ដោយសហគមន៍កសកម្មដល់សមាជិក។

-------------------------------------------------------------------

# ជំពូកទី៧

# ការចូលរួមរបស់សមាជិកនៅក្នុងសហគមន៍កសិកម្ម

យោងទៅតាមការអនុវត្តទូទៅ សមាជិកទាំងអស់ គួរតែចូលរួមនៅក្នុងកិច្ចប្រជុំទាំងអស់របស់សហគមន៍កសិកម្ម។ ការចូលរួមកាន់តែច្រើន គឺបង្ហាញពីភាពកាន់តែល្អប្រសើររបស់សហគមន៍កសិកម្ម។ វាគឺជាតួនាទីរបស់ភាពជាអ្នកដឹកនាំរបស់សហគមន៍កសិកម្មក្នុងការជំរុញសមាជិកឱ្យចូលរួមគ្រប់សកម្មភាព។

ការចូលរួមមានន័យបីយ៉ាងគឺទី១ ការចូលរួមនៅក្នុងប្រព័ន្ធរចនាសម្ព័ន្ធបែបប្រជាធិបតេយ្យរបស់សហគមន៍កសិកម្ម ទី២ ការចូលរួមនៅក្នុងការប្រតិបត្តិការមុខរបររបស់សហគមន៍កសិកម្ម ទី៣ ការចូលរួមនៅក្នុងដើមទុនរបស់សហគមន៍កសិកម្ម។

ការចូលរួមនៅក្នុងប្រព័ន្ធរចនាសម្ព័ន្ធបែបប្រជាធិបតេយ្យរបស់សហគមន៍កសិកម្ម មានន័យថាការចូលរួមកាន់តែច្រើននៅក្នុងកិច្ចប្រជុំមហាសន្និបាត។ នេះសំដៅលើការពិភាក្សាយ៉ាងល្អប្រសើរ និងសេចក្តីសម្រេចដែលល្អនិងអាចទទួលយកបាន។ ប្រជាធិបតេយ្យភាពកាន់តែមាន នៅពេលដែលមានសមាជិកជាច្រើនចូលរួមនៅក្នុងកិច្ចប្រជុំមហាសន្និបាត។ ចំនួនចូលរួមកាន់តែតិច មានន័យថាដូចប្រគល់អំណាចក្នុងការគ្រប់គ្រងសហគមន៍កសិកម្មទៅឱ្យអ្នកណាម្នាក់។ ភាពជាម្ចាស់ នឹងចាកឆ្ងាយពីសមាជិកទាំងអស់។

សមាជិកទាំងអស់ ត្រូវតែអាចបោះឆ្នោតនិងបញ្ចេញមតិដោយសេរីនិងយុត្តិធម៌។ ការចូលរួមនៅប្រព័ន្ធរចនាសម្ព័ន្ធបែបប្រជាធិបតេយ្យរបស់សហគមន៍កសិកម្ម មានន័យថាការពិភាក្សាដ៏ប្រសើរ ការសម្រេចដ៏ល្អ ការបង្កើនភាពជិតស្និទ្ធនិងទុកចិត្ត ក្នុងការយល់ឃើញរបស់សហគមន៍រស់នៅ។ វាក៏បង្ហាញពីសាមគ្គីភាពរបស់សមាជិកជាមួយនឹងសហគមន៍កសិកម្មរបស់ពួកគេ។

ការចូលរួមក្នុងកិច្ចការមុខជំនួញរបស់សហគមន៍កសិកម្ម គឺជាការចាំបាច់ផងដែរ ។ សមាជិកទាំងអស់ គួរតែចូលរួមធ្វើជំនួញជាមួយនិងតាមរយៈសហគមន៍។ នៅពេលសមាជិក ទទួលឥណទានពីសហគមន៍កសិកម្មសម្រាប់ផលិតកម្មកសិកម្ម សមាជិកត្រូវបានតម្រូវឱ្យលក់ផលិតផលរបស់ខ្លួនតាមរយៈសហគមន៍ ហើយពួកគេទិញជាតុចូលកសិកម្មពីសហគមន៍។ ការចូលរួមធ្វើជំនួញកាន់តែច្រើន គឺពង្រឹងសេដ្ឋកិច្ចរបស់សហគមន៍។

ការប្រាសចាកពីក្រមសីលធម៌ កើតមាននៅពេលដែលសមាជិក ខ្ចីប្រាក់ពីសហគមន៍កសិកម្ម ប៉ុន្តែបែរជាលក់ផលិតផលរបស់ខ្លួនទៅអ្នកដទៃ ដោយមិនខ្វល់ពីប្រភពជំនួយ។ សហគមន៍កសិកម្ម គឺឈរយ៉ាងរឹងមាំសម្រាប់ពេលមានតម្រូវការ។

ការចូលរួមក្នុងដើមទុនរបស់សហគមន៍កសិកម្ម ក៏ជាការចាំបាច់ផងដែរ។ សមាជិកទាំងអស់ គួរតែទិញភាគហ៊ុនបន្ថែមពីសហគមន៍ហើយដាក់ប្រាក់សន្សំនៅក្នុងសហគមន៍។ ប្រាក់ដែលសមាជិកខ្ចីពីសហគមន៍កសិកម្ម គឺជាប្រាក់របស់សមាជិកដទៃ។ បើសិនសមាជិកដាក់ប្រាក់សន្សំបន្តិចបន្តួចនៅក្នុងសហគមន៍នោះមានតែសមាជិកតិចតួចប៉ុណ្ណោះដែលអាចខ្ចីប្រាក់ពីសហគមន៍កសិកម្មបាន។

ទំនាក់ទំនងរវាងសមាជិកនិងសហគមន៍កសិកម្ម មិនគួរកើតមានក្នុងផ្លូវតែមួយនោះទេ គឺគួរកើតមានក្នុងផ្លូវច្រើន ដូចជាសមាជិកដែលទទួលយកឥណទានពីសហគមន៍កសិកម្ម ត្រូវបានរំពឹងថានឹងលក់ផលិតផលរបស់ពួកគេតាមរយៈសហគមន៍ ហើយទិញជាតុចូលកសិកម្មពីសហគមន៍កសិកម្ម។ ម្យ៉ាងវិញទៀត សមាជិកក៏ត្រូវបានគេរំពឹងថានឹងដាក់ប្រាក់សន្សំនៅក្នុងសហគមន៍របស់ខ្លួនដែលអាចអោយសមាជិកដទៃទៀតខ្ចីប្រាក់។ នៅក្នុងដំណើរការបែបនេះ ទាំងសមាជិកនិងសមាជិក នឹងទទួលបានផលចំណេញចំណែកឯសហគមន៍កសិកម្មនឹងទទួលបានកម្រៃជើងសារពីប្រតិបត្តិការមុខរបរ ហើយសមាជិក នឹងអាចលក់ផលិតផលរបស់ខ្លួននៅក្នុងតម្លៃខ្ពស់សមរម្យ ទិញជាតុចូលក្នុងតម្លៃទាប និងខ្ចីប្រាក់ក្នុងអត្រាការប្រាក់ទាប។

ការចូលរួមច្រើននៅក្នុងរចនាសម្ព័ន្ធសហគមន៍កសិកម្ម មុខរបរ និងដើមទុន នឹងលើកកម្ពស់ស្ថានភាពរបស់សហគមន៍កសិកម្ម។ សមាជិកនៅក្នុងសហគមន៍រស់នៅ នឹងមានអារម្មណ៍ចង់ចូលរួមនៅក្នុងសហគមន៍កសិកម្មដែលជាហេតុនាំឱ្យមានការកើនឡើងនូវសមាជិកភាព។

រឿងសំងាត់នៃភាពជោគជ័យរបស់សហគមន៍កសិកម្ម គឺជាការប្រើប្រាស់សេវាច្រើនរបស់សហគមន៍ដោយសមាជិក។ ការប្រើប្រាស់កាន់តែច្រើន ផ្តល់ប្រាក់ចំណូលកាន់តែខ្ពស់ និងផ្តល់ទំនុកចិត្តនិងភាពជឿជាក់កាន់តែខ្ពស់នៅក្នុងប្រតិបត្តិការនិងមុខរបររបស់សហគមន៍កសិកម្ម។ ការប្រើប្រាស់សេវាកាន់តែច្រើនដោយសមាជិក បង្កើនភាពជិតស្និទ្ធក្នុងចំណោមសហគមន៍រស់នៅនិងក្នុងមុខរបរ។

---------------------------------------------------------------

# ជំពូកទី៨

# តម្លាភាពនិងគណនេយ្យភាពនៅក្នុងសហគមន៍កសិកម្ម

សហគ្រាស ឬក្រុមហ៊ុនដែលប្រកបមុខរបរទទួលបានជោគជ័យនៅទូទាំងពិភពលោក ដោយសារពួកគេមានគោលការណ៍តម្លាភាពនិងគណនេយ្យភាពនៅក្នុងការប្រតិបត្តិការមុខរបរ។ សហគមន៍កសិកម្ម ក៏មានភាពដូចគ្នាអញ្ចឹងដែរ ហេតុដូច្នេះសហគមន៍កសិកម្មត្រូវតែអនុវត្តវិធីសាស្ត្រច្បាស់លាស់និងមានតម្លាភាពនៅក្នុងទំនាក់ទំនងសង្គមនិងសេដ្ឋកិច្ច។ មិនមានអ្វីអាចលាក់បាំងនឹងភ្នែករបស់សមាជិកបានឡើយ។ មិនមានសមាជិកណាប្រឆាំងនឹងផលប្រយោជន៍របស់សហគមន៍កសិកម្មរបស់ខ្លួនចំពោះការដឹកនាំ និងមុខងារនោះទេ។

ខាងក្រោមនេះ ជាកត្តាសំខាន់ៗនៃតម្លាភាពនិងគណនេយ្យភាព៖

- រាល់សេចក្តីសម្រេច គួរតែត្រូវបានធ្វើឡើងតាមបែបប្រជាធិបតេយ្យនិងបើកចំហរ

- រាល់សំណើនិងបណ្តឹងរបស់សមាជិក គួរតែត្រូវបានដោះស្រាយភ្លាមៗ

- កំណត់ត្រាកិច្ចប្រជុំនិងរបៀបវារៈ គួរតែត្រូវបានចែកជូនសមាជិកជាមុន

- សមាជិកទាំងអស់ គួរតែដឹងអំពីលក្ខន្តិកៈ។ ពួកគេ គួរតែទទួលបាននូវឯកសារលក្ខន្តិកៈថតចម្លងមួយច្បាប់។

- រាល់សម្ភារៈទាំងអស់របស់សហគមន៍កសិកម្ម គួរតែត្រូវបានប្រើប្រាស់សម្រាប់គោលបំណងជាផ្លូវការ

- អ្នកគ្រប់គ្រងទាំងអស់ គួរតែទទួលបាននូវតារាងតួនាទីនិងទំនួលខុសត្រូវរាងៗខ្លួន

- ក្រមសីលធម៌សម្រាប់អ្នកទាំងអស់គ្នា គួរតែត្រូវបានរៀបចំនិងចែកជូន

- វិក័យប័ត្រ គួរតែត្រូវបានចេញសម្រាប់រាល់ការចំណាយ ដែលធ្វើឡើងដោយសមាជិកនិងអតិថិជនសម្រាប់សហគមន៍កសិកម្ម

- មូលនិធិផ្ទាល់ខ្លួននិងសហគមន៍កសិកម្ម គួរតែត្រូវបានរាប់ជាច់ដោយឡែកពីគ្នា

- រាល់សៀវភៅមូលប្បទានប័ត្រ កាតឥណទាន និងសៀវភៅធនាគារ គួរតែត្រូវបានរក្សាទុកដោយសមាជិកខ្លួនឯងផ្ទាល់

- មិនត្រូវអោយសៀវភៅមូលប្បទានប័ត្រដែលមានចុះហត្ថលេខាត្រឹមត្រូវ រក្សាទុកដោយនាយកគ្រប់គ្រងនោះទេ

- រាល់សៀវភៅគណនីទាំងអស់ គួរតែត្រូវបានធ្វើបច្ចុប្បន្នភាពគ្រប់ពេលវេលា

- រាល់របាយការណ៍គណនីត្រឹមត្រូវ គួរតែត្រូវបានរៀបចំនិងបង្ហាញនៅក្នុងកិច្ចប្រជុំមហាសន្និបាត

- សវនកម្ម គួរតែត្រូវបានអនុវត្តឱ្យបានទាន់ពេលវេលា ហើយរបាយការណ៍ ត្រូវបានបង្ហាញនៅក្នុងកិច្ចប្រជុំមហាសន្និបាត

- រាល់ការជួល គួរតែត្រូវបានធ្វើឡើងក្នុងលក្ខណ្ឌត្រឹមត្រូវនិងយោងទៅតាមនិតិវិធីដែលបានកំណត់

សហគមន៍កសិកម្មណា ដែលប្រព្រឹត្តទៅជាមួយនឹងគោលការណ៍តម្លាភាពនិងគណនេយ្យភាពនិងជាមួយនឹងគោលការណ៍គ្រឹះសហគមន៍កសិកម្ម នឹងក្លាយជាសហគមន៍ដែលមានប្រសិទ្ធភាពនិងទទួលបានការគោរព ហើយសមាជិកនៅក្នុងសហគមន៍រស់នៅ នឹងចង់មានទំនាក់ទំនងជាមួយសហគមន៍កសិកម្មប្រភេទនេះ។

---

# ជំពូកទី៩

# ការបង្កើនសមាជិកភាព ប្រាក់ភាគហ៊ុន និងអភិបាលកិច្ចនៅក្នុងសហគមន៍កសិកម្ម

ដើម្បីលើកកម្ពស់សមាជិកភាពនិងប្រាក់ភាគហ៊ុន វាជាកាចាំបាច់ណាស់ដែលត្រូវមានការអប់រំទូលំទូលាយដល់សមាជិកសហគមន៍និងព័ត៌មានអំពីភាពជោគជ័យនៃសហគមន៍កសិកម្ម។ គោលបំណងនៃការអប់រំសមាជិក គឺដើម្បីពន្យល់ពីសារប្រយោជន៍នៃសមាជិកភាពច្រើន និងកំរិតខ្ពស់សមរម្យនៃប្រាក់ភាគហ៊ុនដើម្បីរក្សាមុខរបរឱ្យមានដំណើរការទៅមុខបាន។

ហេតុដូច្នេះ ខាងក្រោមនេះគឺជាគំនិតគួរយកមកពិចារណា៖

## ក) យុទ្ធវិធីបង្កើនសមាជិកភាព

- ធ្វើឱ្យសមាជិកបានយល់ពីបទបញ្ញត្តិនៃលក្ខន្តិកៈរបស់សហគមន៍កសិកម្ម ដោយរៀបចំកិច្ចប្រជុំជាទៀងទាត់ទៅលើបទបញ្ញត្តិសំខាន់ៗ

- សមាជិក គួរតែមានការជឿជាក់និងមានទំនុកចិត្តនៅក្នុងការដឹកនាំ សម្រាប់ភាពប្រសើរឡើងនៃសហគមន៍កសិកម្មរបស់ពួកគេ

- សមាជិកបានយល់ពីគោលការណ៍គ្រឹះសហគមន៍កសិកម្មដើម្បីទទួលបានផលប្រយោជន៍ជាវិជ្ជមានពីសហគមន៍កសិកម្ម ជាជាងត្រូវបានដឹកនាំខុសទៅតាមទំរង់របស់សហគ្រាសអាជីវកម្មដទៃទៀត

- ពន្យល់ដល់សមាជិកនិងសាធារណជនទូទៅ អំពីនិយមន័យនៃសហគមន៍កសិកម្ម និងដកស្រង់យកចំណុចសំខាន់នៃការប្រកបមុខរបរជាមួយសហគមន៍កសិកម្ម

- បញ្ជាក់ទៅលើការសងប្រាក់កម្ចីទាំងអស់ជាមួយនឹងការប្រាក់ឱ្យបានទាន់ពេលវេលារបស់សមាជិក ។ ការធ្វើបែបនេះ ពង្រឹងសេដ្ឋកិច្ចរបស់សហគមន៍កសិកម្មក៏ដូចជាផ្តល់ឱកាសដល់សមាជិកដទៃទៀតក្នុងការទទួលប្រាក់កម្ចី

- បញ្ជាក់ទៅសមាជិកថាបើសិនពួកគេខ្ចីពីសហគមន៍កសិកម្មសម្រាប់ផលិតកម្មកសិកម្ម វាជាការចាំបាច់ដែលពួកគេត្រូវលក់ផលិតផលរបស់ពួកគេតាមរយៈសហគមន៍

- អនុវត្តយ៉ាងតឹងរឹងនូវគោលការណ៍គណនេយ្យភាពនិងតម្លាភាព ដើម្បីទទួលបានការជឿជាក់ពីសមាជិក

- រាល់វិក័យប័ត្រ ត្រូវបានចេញសម្រាប់រាល់ការបង់ប្រាក់ ដើម្បីផ្តល់ជូនសហគមន៍កសិកម្ម

- រៀបចំការអប់រំសម្រាប់សមាជិក និងកម្មវិធីបណ្តុះបណ្តាល់បុគ្គលិកជាទៀងទាត់ ដើម្បីពិភាក្សាពីផែនការរបស់សហគមន៍កសិកម្ម និងទទួលសំណើពីសមាជិក

- សហគមន៍កសិកម្មដែលមានដំណើរការយ៉ាងរលូន ជំរុញដល់សមាជិកនៅក្នុងសហគមន៍រស់នៅឱ្យក្លាយជាសមាជិកសហគមន៍កសិកម្ម ដែលជាហេតុធ្វើឱ្យមានការកើនឡើងនៃសមាជិកភាពនិងប្រភពចំណូល

- រំលឹកសមាជិកពីទស្សនវិស័យ បេសកកម្ម និងគោលបំណងរបស់សហគមន៍កសិកម្ម ។ ទាំងនេះ ត្រូវបានសរសេរយ៉ាងលម្អិតនៅក្នុងលក្ខន្តិកៈ ។ សមាជិក គួរតែបានដឹងពីបទបញ្ញត្តិរបស់លក្ខន្តិកៈ ។

- ប្រើប្រាស់ការអប់រំសមាជិកក្នុងគោលបំណងពន្យល់ពីបទបញ្ញត្តិនៃលក្ខន្តិកៈ សារៈសំខាន់នៃការគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យ និងការចូលរួមរាល់កិច្ចការនៅក្នុងសហគមន៍

- ជំរុញឱ្យចូលរួមក្នុងសហគមន៍ ដោយពន្យល់ពីសារប្រយោជន៍នៃការក្លាយជាសមាជិក និងផលចំណេញដែលសមាជិកទទួលបានពីការខំប្រឹងប្រែងរួមគ្នារបស់សហគមន៍កសិកម្ម

- លើកកម្ពស់ស្មារតីនិងជំនាញ នៅក្នុងចំណោមសមាជិកនិងបុគ្គលិក

- បង្ហាញពីផលចំណេញដល់សមាជិក/សាធារណជនទូទៅ តាមរយៈយុទ្ធនាការសាធារណៈ និងកិច្ចប្រជុំផ្ទាល់ខ្លួន

- បង្ហាញពីករណីជោគជ័យដល់សមាជិកនិងសាធារណជនទូទៅ ក្នុងកំឡុងពេលកិច្ចប្រជុំជាសាធារណៈ និងឱកាសរីករាយផ្សេងៗ

- សរសេររឿងជោគជ័យសាមញ្ញៗ ដែលងាយស្រួលយល់និងអនុវត្តនៅក្នុងចំណោមសមាជិករបស់សហគមន៍រស់នៅ

- ប្រើប្រាស់បុគ្គលសាសនានិងបុគ្គលសង្គមដែលមានភាពល្បីល្បាញ មន្ត្រីរដ្ឋាភិបាលដើម្បីផ្សព្វផ្សាយពីមុខងារពិតប្រាកដរបស់សហគមន៍កសិកម្ម និងបញ្ជាក់ទៅលើការប្រើប្រាស់ប្រាក់កម្ចីត្រឹមត្រូវ

- សហគមន៍កសិកម្ម គឺជាអង្គការតែមួយដែលជួយសមាជិកនៅក្នុងគ្រាលំបាក ហើយសហគមន៍កសិកម្មគួរតែផ្សព្វផ្សាយការពិតទាំងនេះដល់សមាជិក

- បញ្ជាក់ពីស្ថានភាពបរាជ័យរបស់សហគមន៍កសិកម្ម ។ សកម្មភាពនេះ ផ្តល់ព័ត៌មានល្អៗនិងដំបូន្មានដល់សមាជិក

- បង្កើតឱ្យមានការប្រើប្រាស់នៃក្រុមអ្នកជួយខ្លួនឯង ក្រុមកសិករ ក្រុមជារាសាស្ត្រ ក្រុមអ្នកដាំដុះ

- រៀបចំកិច្ចប្រជុំក្នុងសហគមន៍រស់នៅជាទៀងទាត់ និងនៅកន្លែងដែលផ្តល់ភាពងាយស្រួលដល់សមាជិកបុរសនិងស្ត្រី

- អនុវត្តវិធានការនៃអភិបាលកិច្ចល្អ តាមរយៈការចូលរួមយ៉ាងសកម្មរបស់សមាជិក និងគោរពទៅតាមលក្ខន្តិកៈនិងគោលការណ៍សហគមន៍កសិកម្ម

- ពង្រីកការចូលរួមសមាជិកនៅក្នុងរចនាសម្ព័ន្ធប្រជាធិបតេយ្យ (ដូចជាការប្រជុំ) និងការប្រតិបត្តិមុខរបរ

- ពង្រីកការចូលរួមរបស់បុគ្គលិក ក្នុងផ្នត់គំនិតផ្តល់សេវាកម្មឆាប់និងមានប្រសិទ្ធភាពដល់សមាជិកនិងដើម្បីធ្វើឱ្យមានទំនាក់ទំនងល្អក្នុងចំណោមសមាជិក សមាជិកក្រុមប្រឹក្សាភិបាល និងបុគ្គលិក

- សហគមន៍កសិកម្ម បង្កើតភាពជិតស្និទ្ធកាន់តែខ្លាំង បើសិនពួកគេទិញរាល់ផលិតផលរបស់សមាជិក

- គោលការណ៍សហគមន៍ទី១ (ការចូលរួមដោយស្ម័គ្រចិត្តនិងបើកចំហររបស់សមាជិកភាព) និងគោលការណ៍ទី៥ (ការអប់រំ ការបណ្តុះបណ្តាល និងការផ្តល់ព័ត៌មាន) គឺជាគោលការណ៍ចំបងក្នុងការបង្កើនសមាជិកភាព ។ គោលការណ៍ទី៣ (ការចូលរួមផ្នែកសេដ្ឋកិច្ចរបស់សមាជិក) ផ្តោតសំខាន់លើការពង្រឹងមូលនិធិរបស់សហគមន៍ ពិសេសតាមរយៈប្រាក់ភាគហ៊ុន និងការបង្កើនទុន ។ ទាំងនេះ គឺចាំបាច់ត្រូវពន្យល់យ៉ាងច្បាស់លាស់ដល់សមាជិក

- ដោយរក្សានូវគំនិតនៃរចនាសម្ព័ន្ធរបស់សហគមន៍និងការគ្រប់គ្រង តម្រូវការរបស់សមាជិក ត្រូវបានបំពេញដោយប្រភពធនធានរបស់ខ្លួន។ ដើម្បីបានយល់ដឹងពីរចនាសម្ព័ន្ធនិងការគ្រប់គ្រងរបស់សហគមន៍កសិកម្ម ការពិនិត្យមើលជំហាននៃការរៀបចំសហគមន៍កសិកម្ម គឺពិតជាមានប្រយោជន៍។

ជំហានទាំងនេះ បង្ហាញយ៉ាងច្បាស់ថាសហគមន៍កសិកម្ម គឺខុសគ្នាពីសហគ្រាសឯកជន និងមានភាពស្និទ្ធស្នាលជាមួយសមាជិក។ ពួកគេគឺជាសហគ្រាសស្របច្បាប់និងផ្តល់ការការពារដល់សមាជិកនិងទ្រព្យសម្បត្តិ។ បើសិនជំហានទាំងនេះ ត្រូវបានពន្យល់ដល់សមាជិក នោះនឹងមានការកើនឡើងនូវសមាជិកភាពក៏ដូចជាប្រាក់ភាគហ៊ុន។

ការចូលរួមប្រើមនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រង គឺសំខាន់ណាស់ក្នុងការបង្កើតភាពជិតស្និទ្ធដល់សហគមន៍កសិកម្មក្នុងចំណោមសមាជិក។ នៅពេលសេវាកម្ម ដែលត្រូវបានផ្តល់ដោយសហគមន៍មានប្រសិទ្ធភាពបានទាន់ពេលវេលានិងតាមតម្រូវការ មនុស្សជាច្រើន នឹងមកចូលរួមនៅក្នុងសហគមន៍កសិកម្ម និងការអភិវឌ្ឍមុខរបរ។ ពួកគេ នឹងមានភាពរីករាយក្នុងការទិញភាគហ៊ុនកាន់តែច្រើន។

ជាការកត់សំគាល់ សហគមន៍កសិកម្មជាច្រើននៅក្នុងប្រទេសកម្ពុជា បានសន្យាថានឹងផ្តល់ប្រាក់ភាគលាភខ្ពស់ (ពី២០% ទៅ៣០%ក្នុងមួយភាគហ៊ុនក្នុងមួយឆ្នាំ) ដល់កសិករដើម្បីបង្កើនសមាជិកភាព ហើយប្រាក់ចំណេញភាគច្រើនរបស់សហគមន៍កសិកម្មទាំងនោះ ត្រូវបានផ្តល់ឱ្យសមាជិកជាប្រាក់ភាគលាភ។ ថ្នាក់ដឹងនាំសហគមន៍កសិកម្ម ជាទូទៅយល់ច្រឡំថាសហគមន៍កសិកម្ម គឺដូចនឹងក្រុមហ៊ុនដែលផ្តល់ប្រាក់ភាគលាភខ្ពស់ដល់សមាជិកដែរ។ នេះក៏ព្រោះតែថ្នាក់ដឹកនាំសហគមន៍កសិកម្មនៅក្នុងប្រទេសកម្ពុជាមិនទាន់បានយល់ច្បាស់ពីគោលការណ៍សហគមន៍និងលក្ខណៈរបស់សហគមន៍កសិកម្ម។

សហគមន៍កសិកម្ម ត្រូវបានផ្សារភ្ជាប់ជាមួយសមាជិករបស់ខ្លួនតាមរយៈការផ្តល់និងការប្រើប្រាស់មុខរបរ មិនមែនផ្សារភ្ជាប់តាមរយៈការបង់និងទទួលបាននូវប្រាក់ភាគលាភខ្ពស់នោះទេ។ ថ្នាក់ដឹកនាំសហគមន៍កសិកម្ម ត្រូវតែយល់ឱ្យបានច្បាស់លាស់ពីគោលការណ៍សហគមន៍ ពិសេសគោលការណ៍គ្រឹះទី៣ សមាជិកតែងតែទទួលបានប្រាក់ភាគលាភមានកំណត់ "(ការកំណត់ប្រាក់ភាគលាភ)" ហើយព្យាយាមបង្កើនសមាជិកភាពតាមរយៈការផ្តល់នូវមុខរបរសំខាន់ៗសម្រាប់សមាជិក ដោយមិនមែនជាការបង់ប្រាក់ភាគលាភខ្ពស់នោះទេ។

សហគមន៍កសិកម្មនៅក្នុងប្រទេសកម្ពុជា គួរតែបែងចែកប្រាក់លើកទឹកចិត្តដល់សមាជិកឱ្យបានច្រើន ពីប្រាក់ចំណេញដោយយោងទៅតាមចំនួននៃការប្រើប្រាស់មុខរបរដោយសមាជិកនីមួយៗ ជំនួសអោយការផ្តល់ប្រាក់ភាគលាភ។

## ខ) យុទ្ធវិធីបង្កើនប្រាក់ភាគហ៊ុន

វាគួរតែត្រូវបានចងចាំដែរថា សមាជិកក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្ម និង អ្នកអភិវឌ្ឍសហគមន៍កសិកម្មគួរតែជំរុញការបង្កើនប្រាក់ភាគហ៊ុននិងបញ្ញើសន្សំនៅក្នុងដើមទុន។ ដើមទុន គឺជាទ្រព្យសម្បត្តិ ហើយវាមិនគួរត្រូវបានទុកសម្រាប់បែងចែកដល់សមាជិកដោយមិនប្រុងប្រយ័ត្ននោះទេ។ សេចក្តីសម្រេចក្នុងការប្រើប្រាស់ដើមទុន ត្រូវតែធ្វើឡើងដោយសមហេតុផល។ ដើមទុនដែលបានកៀងគរ គឺមិនមែនសម្រាប់តែផ្តល់ប្រាក់កម្ចីនោះទេ។

គោលការណ៍ទី៣ នៃគោលការណ៍គ្រឹះរបស់សហគមន៍កសិកម្មបានពន្យល់ថា "សមាជិក ជាទូទៅទទួលបានប្រាក់ភាគលាភមានកំណត់ បើសិនជាមាន ចំពោះដើមទុនដែលបានចូលរួមក្នុងលក្ខណ្ឌជាសមាជិកភាព ។ សមាជិក បែងចែកប្រាក់ចំណេញទៅតាមគោលបំណងដូចខាងក្រោម៖ ការអភិវឌ្ឍសហគមន៍ដោយបង្កើតជាមូលនិធិបម្រុងដែលជាផ្នែកមិនអាចបែងចែក ការផ្តល់ប្រាក់លើកទឹកចិត្តដល់សមាជិកក្នុងសមាមាត្រនៃការប្រតិបត្តិការជំនួញជាមួយសហគមន៍ និងការគាំទ្រសកម្មភាពផ្សេងៗទៀត ដែលបានសម្រេចដោយសមាជិក"។ នៅក្នុងអត្ថន័យនៃសេចក្តីណែនាំនេះ រាល់ចំណូលទាំងអស់ (ប្រាក់ភាគហ៊ុន ប្រាក់បញ្ញើសន្សំ និងមូលនិធិផ្សេងៗទៀត) ត្រូវតែរក្សាទុកហើយប្រើប្រាស់នៅក្នុងផ្លូវត្រូវ ដោយមិនត្រូវទុកសម្រាប់ជាប្រាក់កម្ចីទាំងអស់ឡើយ ដោយមិនបានទុកអ្វីសោះជាទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្មនោះទេ។

វាគួរតែត្រូវបានកត់ចំណាំថា កសិករដែលជាសមាជិកមានធនធាន អាចប្រើប្រាស់សម្ភារៈនិងហេដ្ឋារចនាសម្ព័ន្ធបានយ៉ាងស្រួលដោយប្រើប្រាស់មូលនិធិផ្ទាល់ខ្លួន ប៉ុន្តែកសិករដែលជាសមាជិកមិនសូវមានធនធានពឹងផ្អែកខ្លាំងលើមូលនិធិដែលផ្តល់ដោយសហគមន៍កសិកម្ម។ សហគមន៍កសិកម្ម អាចផ្តល់ប្រាក់កម្ចីបានលុះត្រាតែមាននៅសល់នៅក្នុងមូលនិធិបម្រុងនិងបញ្ញើសន្សំ។ ហេតុដូច្នេះ វាពិតជាមានសារៈសំខាន់ដែលថាមន្ត្រីរដ្ឋាភិបាល អ្នកអភិវឌ្ឍន៍ និងសមាជិកក្រុមប្រឹក្សាភិបាល មិនត្រូវផ្តល់ដំបូន្មានក្នុងការផ្តល់ប្រាក់កម្ចីដោយប្រើប្រាស់ប្រាក់បញ្ញើសន្សំទាំងស្រុងនោះទេ។

គោលបំណងសំខាន់នៃការបង្កើតសហគមន៍កសិកម្ម គឺដើម្បីផ្តល់ប្រាក់កម្ចី និងផ្តល់ការគាំទ្រផ្សេងៗដល់សមាជិកដែលក្រីក្រនិងត្រូវការជំនួយ។ គោលបំណងរបស់វា គឺដើម្បីការពារសមាជិកពីការកេងប្រវ័ញ្ចរបស់អ្នកផ្តល់ប្រាក់កម្ចីដទៃផ្សេងទៀត។

- ប្រាក់ភាគហ៊ុន គឺជាមូលនិធិគ្រឹះដែលត្រូវបានប្រើប្រាស់ ដើម្បីប្រតិបត្តិនូវសកម្មភាពមុខជំនួញរបស់សហគមន៍កសិកម្ម។

- សហគមន៍កសិកម្មអាចបង្កើតមូលនិធិស្ម័គ្រចិត្ត បើសិនជាត្រូវការក្រៅពីមូលនិធិដែលត្រូវបានកំណត់ ។

- សាច់ប្រាក់ ត្រូវបានកំណត់នៅក្នុងវគ្គដំបូងតម្រូវឱ្យមានការគ្រប់គ្រងសម្រាប់ការប្រើប្រាស់ដែលមានប្រសិទ្ធិភាព។ វាត្រូវធ្វើឡើងដោយការគ្រប់គ្រងចំណាយ ការកាត់បន្ថយការប្រើប្រាស់ទូរស័ព្ទ ការប្រើប្រាស់ឡាន សកម្មភាពផ្សេងៗ ការប្រារព្ធពិធីបុណ្យ ការប្រារព្ធពិធីអបអរនានា

- ភាពជាម្ចាស់ដោយការទិញភាគហ៊ុនបន្ថែម គឺមានឱកាសក្លាយទៅជាម្ចាស់ភាគហ៊ុនធំ ដោយសមាជិកមានអារម្មណ៍ថា សមាជិកគឺជាអ្នកអភិវឌ្ឍមុខរបររបស់សហគមន៍កសិកម្ម

- គោលការណ៍សហគមន៍ទី៣ (ការចូលរួមផ្នែកសេដ្ឋកិច្ចរបស់សមាជិក) គឺផ្តោតសំខាន់លើការពង្រឹងមូលនិធិរបស់សមាជិក ពិសេសតាមរយៈប្រាក់ភាគហ៊ុន

- សហគមន៍កសិកម្ម អាចពង្រីកការប្រតិបត្តិមុខរបររបស់ខ្លួនបាន បើសិនពួកគេមានមូលនិធិនៅក្នុងដើមទុនរបស់ខ្លួន ។ បើសិនជាប្រាក់ភាគហ៊ុននិងបញ្ញើសន្សំ ត្រូវបានខ្ចីទាំងអស់ នោះនឹងមិនមានសេសសល់អ្វីសម្រាប់អភិវឌ្ឍន៍មុខរបរទៅមុខទៀតទេ

- វាគឺជាតួនាទីរបស់សមាជិកក្រុមប្រឹក្សាភិបាល ដែលត្រូវជំរុញប្រាក់បញ្ញើសន្សំនៅក្នុងសហគមន៍កសិកម្ម។ គួរតែមានការយកចិត្តទុកដាក់ ក្នុងការផ្តល់ប្រាក់ខ្ចីពីមូលនិធិដែលត្រូវបានបង្កើន ។ វាគឺជាការអនុវត្តមិនត្រឹមត្រូវទេចំពោះការផ្តល់ប្រាក់កម្ចីចេញពីដើមទុនទាំងអស់នោះ ។

- គោលការណ៍សហគមន៍ទី៣ បញ្ជាក់ថាការប្រាក់ ឬប្រាក់ចំនេញត្រូវបានកំណត់ទៅលើប្រាក់ភាគហ៊ុនដែលចូលរួមចំណែកដោយសមាជិក (ការកំណត់ប្រាក់ភាគលាភ)។ ភាគហ៊ុនរបស់សហគមន៍ មិនត្រូវបានជួញដូរនៅក្នុងទីផ្សារនោះទេ។ ទាំងនេះ គឺជាភាគលាភដែលត្រូវបានផ្តល់ឱ្យដោយយោងទៅតាមមុខរបរដែលប្រតិបត្តិដោយសមាជិកជាមួយនឹងសហគមន៍។ ដូច្នេះ មុនពេលអនុវត្ត សហគមន៍កសិកម្មដែលទើបនឹងបង្កើតថ្មី មិនត្រូវប្រកាសពីកំរិតខ្ពស់នៃប្រាក់ភាគលាភដល់សមាជិកនោះទេ។

- សហគមន៍កសិកម្ម ផ្តល់ការការពារយ៉ាងល្អដល់អ្នកដាក់ប្រាក់បញ្ញើសន្សំនិងផ្តល់សេវាកម្មមួយចំនួន។ ពួកគេ ក៏ផ្តល់នូវអត្រាការប្រាក់សមរម្យទៅការបញ្ញើសន្សំផងដែរ។

- វាតម្រូវឱ្យមានការរៀបចំគម្រោង ការលើកទឹកចិត្ត ការជំរុញ និងការខិតខំប្រឹងប្រែង ក្នុងការគ្រប់គ្រងមូលនិធិរបស់សហគមន៍កសិកម្ម

- ផ្តល់ប្រាក់លើកទឹកចិត្ត ការបញ្ចុះតម្លៃនិងអំណោយដល់សមាជិកដើម្បីធ្វើឱ្យមុខរបរមានការរីកចម្រើន ។ ការផ្តល់បែបនេះ ជាទូទៅទាក់ទងជាមួយនឹងកម្មវិធីសំខាន់ៗមួយចំនួនដូចជាពិធីបុណ្យ មហាសន្និបាត ការប្រារព្ធពិធីជាតិ និងពិធីតាមតំបន់ផ្សេងៗទៀត

- សហគមន៍កសិកម្ម គឺជាអង្គការតែមួយគត់ ដែលជួយដល់សមាជិកក្នុងគ្រាលំបាក

- ការបង្កើនតម្លៃភាគហ៊ុន បើសិនចាំបាច់ បានន័យថាចំនួនប្រាក់កម្ចីច្រើន ត្រូវបានផ្តល់ដល់សមាជិក។ សមាជិក អាចធ្វើការកែប្រែលក្ខន្តិកៈដើម្បីបង្កើនប្រាក់ភាគហ៊ុន

- ការផ្សព្វផ្សាយពីប្រាក់លើកទឹកចិត្តសមាជិក ក៏បង្កើតនូវអារម្មណ៍ល្អនៅក្នុងសហគមន៍រស់នៅជិតខាង ក្នុងការបង្កើនសមាជិក។ ដើម្បីរក្សាធនធានផ្ទាល់ខ្លួនបាននិងបង្កើនមូលនិធិសម្រាប់ផ្តល់ប្រាក់កម្ចីនិងប្រតិបត្តិមុខរបរ ការកាត់បន្ថយការចំណាយលើរាល់ការប្រតិបត្តិការ គួរតែពិចារណា។ ការប្រើប្រាស់សម្ភារៈដែលមានប្រសិទ្ធភាព ធ្វើឱ្យមុខរបរនិងសេវាកម្មមានភាពរីកចម្រើន។

- បង្កើនដើមទុនពីប្រាក់ចំណេញដោយរក្សាទុកនូវប្រាក់ចំណេញរក្សាទុកនិងមូលនិធិស្ម័គ្រចិត្ត

## គ) អភិបាលកិច្ចនៅក្នុងសហគមន៍កសិកម្ម

វាគឺជាការពិតណាស់ដែលថា នៅពេលសមាជិកមានចំណាប់អារម្មណ៍នៅក្នុងសហគមន៍ វាមានសារៈសំខាន់ណាស់ចំពោះរាល់សកម្មភាពអភិវឌ្ឍរបស់សហគមន៍កសិកម្ម។ ស្របពេលគ្នានេះដែរ វាក៏សំខាន់ដែរថាតម្រូវការរបស់សមាជិកនិងការលើកទឹកចិត្ត ត្រូវបានបំពេញដោយសហគមន៍កសិកម្មរបស់ពួកគេ ។ នេះអាចទៅរួច បើសិនមានគោលការណ៍នៃអភិបាលកិច្ចនិងការគ្រប់គ្រងត្រឹមត្រូវចំពោះសមាជិក ក្នុងការដោះស្រាយនិងការធ្វើសេចក្តីសម្រេច។

- រាល់សេចក្តីសម្រេច គួរតែយោងទៅតាមបំណងប្រាថ្នារបស់សមាជិក

- រាល់សេចក្តីសម្រេច ត្រូវបានធ្វើឡើងដោយប្រជាធិបតេយ្យ

- សមាជិកទាំងអស់ ត្រូវបានទទួលស្គាល់និងផ្តល់តម្លៃនៅក្នុងការគ្រប់គ្រងនិងកិច្ចការរបស់សហគមន៍កសិកម្ម

- វាគួរតែមានគោលនយោបាយបើកចំហររវាងក្រុមប្រឹក្សាភិបាលនិងនាយកគ្រប់គ្រង និងរវាងការគ្រប់គ្រងនិងសមាជិកភាពទូទៅ

- សមាជិកទាំងអស់ គួរតែបានយល់ដឹងពីឥទ្ធិពលនៃបទបញ្ញត្តិផ្សេងៗរបស់លក្ខន្តិកៈ ដូចជាកិច្ចប្រជុំ សិទ្ធិ និងតួនាទីជាដើម

- រាល់ការចំណាយ ដែលត្រូវបានទទួលនិងធ្វើឡើង គួរតែត្រូវបានកត់ត្រាទុកយ៉ាងសុក្រិតនិងមានប្រសិទ្ធភាព និងមិនមានអ្វីលាក់បាំងពីសមាជិកនោះទេ។

- អនុវត្តវិធីសាស្ត្រនៃអភិបាលកិច្ចល្អ តាមរយៈការចូលរួមយ៉ាងសកម្មរបស់សមាជិកនិងការគោរពតាមលក្ខន្តិកៈនិងគោលការណ៍សហគមន៍កសិកម្ម

- សមាជិកទាំងអស់ គួរតែទទួលបានការអប់រំទៅលើមូលដ្ឋានគ្រឹះទូទៅ ហើយបុគ្គលិកទាំងអស់ គួរតែទទួលបានការបណ្តុះបណ្តាលផ្នែកជំនាញផងដែរ។

- គោលការណ៍នៃ "តម្លាភាព" និង "គណនេយ្យភាព" គួរតែត្រូវបានដើរតាមយ៉ាងមានប្រសិទ្ធភាព

- ក្រុមប្រឹក្សាភិបាល គួរតែរក្សាការប្រើប្រាស់បានដល់សមាជិក

- វាជាតួនាទីរបស់ក្រុមប្រឹក្សាភិបាលក្នុងការជំរុញសមាជិកឱ្យនាំសមាជិកចូលបន្ថែម និងចូលរួមនៅក្នុងហិរញ្ញវត្ថុរបស់សហគមន៍កសិកម្ម ។ អភិបាលកិច្ចដែលមានភាពស្មោះត្រង់ គោលបំណងល្អគឺជាកត្តាសំខាន់ក្នុងការបង្កើនសមាជិកភាពនិងហិរញ្ញវត្ថុនៅក្នុងសហគមន៍កសិកម្ម។

- គួរមានការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបន្ថែមដល់អ្នកអភិវឌ្ឍន៍សហគមន៍កសិកម្ម អំពីគោលគំនិតសហគមន៍ដើម្បីអោយអាចផ្តល់ដំបូន្មានបានត្រឹមត្រូវដល់សហគមន៍កសិកម្ម។

-----------------------------------------------------------------------

## អំពីអ្នកនិពន្ធ

**លោក** Masahiro MATSUDA ដែលជាជនជាតិជប៉ុននិងកំពុងធ្វើការនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រទេសកម្ពុជា ក្នុងនាមជាអ្នកជំនាញលើការអភិវឌ្ឍសហគមន៍កសិកម្ម។ គាត់ត្រូវបានស្នើឱ្យមកកាន់ប្រទេសកម្ពុជា ដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន និងដោយអតីតប្រធាននៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ សហភាពកណ្តាលនៃសហគមន៍កសិកម្មនៃប្រទេសជប៉ុន និងធ្លាប់ធ្វើជាអ្នកជំនាញការនៅក្រសួងកសិកម្មនិងអភិវឌ្ឍន៍ជនបទនៅក្នុងប្រទេសវៀតណាម។ គាត់ក៏ធ្លាប់ធ្វើជាអ្នកតំណាងអន្តរជាតិនៃសហភាពកណ្តាលនៃសហគមន៍កសិកម្មនៃប្រទេសជប៉ុន ទៅលើគណកម្មាធិការនៃសម្ព័ន្ធសហគមន៍អន្តរជាតិ និងបណ្តាញសម្រាប់ការអភិវឌ្ឍសហគមន៍កសិកម្មសម្រាប់ទ្វីបអាស៊ីនៃអង្គការស្បៀងអាហារនិងកសិកម្ម ។

**លោក** Daman PRAKASH ដែលជាជនជាតិឥណ្ឌានិងជាប្រធានមជ្ឈមណ្ឌលគ្រប់គ្រងនិងអភិវឌ្ឍន៍ជនបទ និងធ្លាប់ជាអតីតប្រធានសម្ព័ន្ធសហគមន៍អន្តរជាតិប្រចាំអាស៊ីប៉ាស៊ីហ្វិច និងធ្លាប់ធ្វើជាប្រធានទីប្រឹក្សាបច្ចេកទេសនៃគម្រោងគ្រប់គ្រងសហគមន៍របស់អង្គការពលកម្មអន្តរជាតិ នៅប្រទេសឥណ្ឌូនេស៊ី និងធ្លាប់ជាអតីតទីប្រឹក្សារបស់អង្គការស្បៀងអាហារនិងកសិកម្មរបស់អង្គការសហប្រជាជាតិ និងធ្លាប់ជាអតីតទីប្រឹក្សាជាន់ខ្ពស់នៃគម្រោងបណ្តុះបណ្តាលគ្រូសហគមន៍នៅប្រទេសស្រីលង្កា របស់មជ្ឈមណ្ឌលសហគមន៍ស៊ុយអែតនៃសម្ព័ន្ធសហគមន៍អន្តរជាតិ និងជាអ្នកសរសេរសៀវភៅបច្ចេកទេសជាច្រើនស្តីពីការអភិវឌ្ឍជនបទនិងសហគមន៍កសិកម្ម។ ។

**MANAGEMENT OF AGRICULTURAL COOPERATIVES**

Printed in August 2016

Published by Department of Agricultural Cooperative Promotion of General Directorate of Agriculture (MAFF)
The Project for Establishing Business Oriented Agricultural Cooperative Models (BPAC)

Address: #54B/49F.St395-656,Sangkat Toeuk Laak 3 Khan Tuol Kok, Phnom penh ,Cambodia,
Phone: (023) 883 427, Fax : (023) 883 427

© The Project for Establishing Business-Oriented Agricultural Cooperative Models

Supported by Japan International Cooperation Agency (JICA)